# អភិធម្មលោកត្ថិរ

## សង្ខេប

ព្រះគ្រូសង្ឃសុមេធ ជន់-វ៉ាន់ (ធម្មបញ្ញោ)
ម. ឧ. អាចារ្យបង្រៀនបំពេញវិជ្ជាធម្មវិន័យ
វត្តឧណ្ណាលោម ក្រុងភ្នំពេញ
រៀបរៀង




បណ្ណាគារ **ជីវខ្លួនឯង** លេខ៣០ស្ទួន
វិថីប៉ាស្ទ័រ ខាងកើតផ្សារធំថ្មី ក្រុងភ្នំពេញ
បោះពុម្ពផ្សាយ

២៤៣.
១៦
LIBRARY
BUDDHIST INSTITUTE
www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org


www.budinst.gov.kh    www.elibraryofcambodia.org

ព្រ ៤៣-១៦

# អភិធម្មសេចក្ដីរ

សង្ខេប

ជំនួយដល់អ្នករៀនធម្មវិន័យ

ថ្នាក់ឯក

BUDDHIST INSTITUTE LIBRARY
១៤.៤.៥៥
08-12

ព្រះគ្រូសង្ឃសុមេធ ជន់-កាំ

(ធម្មបញ្ញោ)

ម. ខ. អាចារ្យបង្រៀនបំពេញវិជ្ជាធម្មវិន័យ

វត្តឧណ្ណាលោម ភ្នំពេញ

រៀបរៀង

ថ្ងៃទី ៣០ មេសា ២៤៩៧/១៩៥៤

www.budinst.gov.kh www.elibraryofcambodia.org

# ឧបត្តិកថា

សៀវភៅអភិធម្ម៧គម្ពីរនេះ កើតឡើងដោយសមប្បធានកិរិយារបស់ខ្ញុំ ដែលខំប្រឹងប្រមូលយកច្បាប់អភិធម្មឯទៀតមករៀបរៀងបង្រៀនពួកនិស្សិតបំពេញវិជ្ជាធម្មវិន័យថ្នាក់ឯក វត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុង ព.ស. ២៤៩៦. គ.ស. ១៩៥៤. លុះរៀបរៀងនឹងបង្រៀនរួចហើយ ខ្ញុំចង់ឲ្យច្បាប់នេះរីកផ្សាយទូទៅដល់ពុទ្ធសាសនិកជនគ្រប់ប្រភេទផង ចង់ឲ្យផលដែលកើតអំពីច្បាប់នេះ ជូនចំពោះទៅវិញ្ញាណក្ខន្ធរបស់ញោមប្រុស-ស្រី ដែលគាត់ចែកឋានទៅកាន់បរលោកនាយផង, ខ្ញុំក៏ឲ្យបងប្អូនបង្កើតដែលធ្វើបុណ្យ យកច្បាប់នេះទៅលែលកបោះពុម្ព ដើម្បីចែកជាធម្មទានក្នុងឱកាសបុណ្យទក្ខិណានុប្បទានជាមួយគ្នា ។

ហេតុនេះ ខ្ញុំសូមឧទ្ទិសផលដែលកើតអំពីធម្មទាននេះ ជូនទៅវិញ្ញាណក្ខន្ធរបស់ឧបាសក ឆន់ និងឧបាសិកា ឆួន ដែលត្រូវជាញោមប្រុស-ស្រីដែលអញ្ជើញទៅកាន់លោកខាងមុខ, សូមឲ្យញោមទទួលយកផលនៃធម្មទាននេះតាមសេចក្ដីពេញចិត្តចុះ រួចសូមឲ្យញោមទាំងពីរបានសោយសេចក្ដីសុខ ចំរើនជាភិយ្យោភាព ព្រមទាំងសូមឧទ្ទិសផលនៃធម្មទាននេះដល់សព្វសត្តនិករទាំងអស់ឲ្យបានសុខ-ចំរើនជានិរន្តរ៍តទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងការរៀបរៀងធម្មកថានេះ ខ្ញុំសូមអភ័យទោសអំពីសំណាក់ លោកអ្នកប្រាជ្ញទាំងឡាយចំពោះសេចក្ដីដែលភ្លាំងភ្លាត់, ឆ្គាំឆ្គង នឹងមិនរាបសាខ្លះ ។

ព្រះគ្រូសង្ឃសុមេធ

ឆន់-ភ៉ាន់

www.budinst.gov.kh www.elibraryofcambodia.org

# អភិធម្មបេតស្ថិរ

សង្ខេប

…១…

## អត្ថនៃអភិធម្ម

អត្ថនៃអភិធម្មទាំង៧គម្ពីរនោះ មានសេចក្តីល្អិតក្រៃពេកពោល ដោយប្រភេទមាន ៤ ប្រការគឺ ១- ចិត្ត; ២- ចេតសិក; ៣- រូប; ៤- និព្វាន ដោយប្រការដូច្នេះឯង ។

## អធិប្បាយអំពីប្រភេទ ៤ ប្រការ

១- ពាក្យថា ចិត្ត បានដល់ធម្មជាតិដែលគិតនឹកត្រិះរិះឬសន្សំនូវអារម្មណ៍ហើយដឹងនូវលក្ខណៈនៃអារម្មណ៍, ចិត្តនោះមាន ៨៩ ឬ ១២១ ។

២- ពាក្យថា ចេតសិក បានដល់ធម្មជាតិដែលកើតលេចទទួលអារម្មណ៍ សំដៅយកវត្ថុជាអារម្មណ៍ ជាមួយនឹងចិត្ត, ចេតសិកនោះមាន ៥២ ។

៣- ពាក្យថា រូប បានដល់ធម្មជាតិដែលប្រែប្រួលឬវិនាសដោយហេតុផ្សេងៗ មានក្តៅត្រជាក់ជាដើមតែអ្វីៗ ដែលកើតឡើងប្រាកដដល់ភ្នែក, រូបនោះមាន ២៨ ។

៤- ពាក្យថា និព្វាន បានដល់ធម្មជាតិដែលផុតចាកកិលេសតណ្ហា រលត់បញ្ចក្ខន្ធ គឺលោកុត្តរធម៌ទី ៩ ដែលកើតអំពីលោកុត្តរៈទាំង ៨ ជាដើម, និព្វាននោះ មាន ២ ក៏មាន, មាន ៣ ក៏មាន ។ មាន២នោះគឺ

www.budinst.gov.kh www.elibraryofcambodia.org

១- ឧប្បាទិសេសៈ, ២-អនុប្បាទិសេសៈ ។ មាន ៣ គឺ ១- សុញ្ញត; ២- អនិមិត្ត; ៣- អប្បណិហិត ។

## ប្រភេទទី ១ ពោលអំពីចិត្ត

ចិត្តនោះមាន ៤ ប្រភេទគឺ:

១– ចិត្តជាកាមាវចរៈ មាន ៥៤;

២– ចិត្តជារូបាវចរៈ មាន ១៥;

៣- ចិត្តជាអរូបាវចរៈមាន ១២;

៤- ចិត្តជាលោកុត្តរៈ មាន៨ ។

រួមជាចិត្ត៨៩ ដោយសង្ខេប បើចែកចិត្តដោយពិស្តារត្រង់លោកុត្តរៈ ចែកចេញទៅដោយឈានប្រាំៗជា៤០ រួមទាំងអស់ ១២១ ។

## អធិប្បាយចិត្តទាំង ៤

១–ពាក្យថា "កាមាវចរ" ចែកចេញជា ២ បទគឺ កាមៈបទ១ អវចរ បទ១, កាម បានដល់កាមភពទាំង១១ជាន់, អវចរ វិលវល់កើតស្លាប់ឬអន្ទោលទៅមក; បានសេចក្តីថា ចិត្តណាដែលត្រាច់ទៅដោយច្រើនក្នុងកាមភព ១១ ជាន់ ចិត្តនោះហៅថា កាមាវចរចិត្ត ។

២–ពាក្យថា "រូបាវចរ" ចែកចេញជា ២ បទគឺ រូបៈបទ ១ អវចរ បទ ១, រូប បានដល់រូបព្រហ្ម ១៦ ជាន់, អវចរ វិលវល់កើត

www.budinst.gov.kh www.elibraryofcambodia.org

ស្លាប់ឬអន្ទោលទៅមក; បានសេចក្ដីថា ចិត្តណាដែលត្រាច់ទៅដោយច្រើនក្នុងរូបព្រហ្ម ១៦ ជាន់ចិត្តនោះហៅថា រូបាវចរចិត្ត ។

៣– ពាក្យថា "អរូបាវចរ" ចែកចេញជា ២ បទគឺ អរូបៈ បទ ១–អវចរ បទ ១, អរូប, បានដល់អរូបព្រហ្ម ៤ ជាន់, អវចរ វិលវល់ កើតស្លាប់ឬអន្ទោលទៅមក; បានសេចក្ដីថា ចិត្តណាដែលត្រាច់ទៅ ដោយច្រើនក្នុងអរូបព្រហ្ម ៤ ជាន់ ចិត្តនោះហៅថា អរូបាវចរចិត្ត ។

៤– ពាក្យថា "លោកុត្តរៈ" ចែកចេញជា ២ បទគឺ លោកៈ បទ ១, ឧត្តរៈ បទ ១, លោកៈ បានដល់លោកទាំង ៣ គឺកាមលោក ១ រូបលោក ១ អរូបលោក ១, ឧត្តរៈ ឆ្លងចាកឬ ឆ្លងផុត, បានសេចក្ដីថាចិត្តណាដែលឆ្លងចាកលោកទាំង ៣ បាន ចិត្តនោះហៅថា លោកុត្តរចិត្ត ។

## កាមាវចរ ៥៤ គឺ:

| | | | |
|---|---|---|---|
| ១– | ចិត្តជាអកុសល | ១២ | អសោភណចិត្ត |
| ២– | " អហេតុក | ១៨ | |
| ៣– | " កាមាវចរសោភណ | ២៤ | |
| | រួមជា | ៥៤ | |

## អកុសល ១២ នោះគឺ :

លោភមូល ៨, ទោសមូល ២, មោហមូល ២ រួមជា ១២ ។

www.budinst.gov.kh www.elibraryofcambodia.org

## លោភមូល ៨ នោះគឺ

១- សោមនស្សសហគតទិដ្ឋិគតសម្បយុត្តអសំខារិក: លោភចិត្តប្រកបដោយសោមនស្សវេទនាព្រមដោយទិដ្ឋិ ២ ប្រការ គឺឧច្ឆេទទិដ្ឋិ សេចក្តីឃើញថាសត្វមានខ្លួននៅក្នុងខ្លួន គឺស្លាប់ហើយសូន្យទៅមិនកើតទៀត១, សស្សតទិដ្ឋិ សេចក្តីឃើញថាសត្វលោកទៀង គឺសត្វស្លាប់ហើយកើតទៀត ធ្លាប់កើតយ៉ាងណា មកកើតជាយ៉ាងនោះទៀត១, មិនប្រកបដោយសំខារ គឺមិនមានបុគ្គលមកដឹកនាំ (ក្លៀវក្លាដោយធម្មតាខ្លួនឯង);

២- សោមនស្សសហគតទិដ្ឋិគតសម្បយុត្តសសំខារិក: លោភចិត្តប្រកបដោយសោមនស្សវេទនា ព្រមដោយទិដ្ឋិ២ ប្រការដូចគ្នា ប្រកបដោយសំខារគឺមានបុគ្គលមកដឹកនាំ (មិនក្លៀវក្លាដោយធម្មតាខ្លួនឯង);

៣- សោមនស្សសហគតទិដ្ឋិគតវិប្បយុត្តអសំខារិក: លោភចិត្តប្រកបដោយសោមនស្សវេទនា វៀរចាកទិដ្ឋិ ២ ប្រការ មិនប្រកបដោយសំខារ ;

៤- សោមនស្សសហគតទិដ្ឋិគតវិប្បយុត្តសសំខារិក: លោភចិត្តប្រកបដោយសោមនស្សវេទនា វៀរចាកទិដ្ឋិ ២ ប្រការប្រកបដោយសំខារ ;

www.budddhist.gov.kh www.elibraryofcambodia.org

៥ - ឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្តអសំខារិ-
កៈ លោភចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយទិដ្ឋិ ២ ប្រការ
មិនប្រកបដោយសំខារ ;

៦ - ឧបេក្ខាសហគតទិដ្ឋិគតសម្បយុត្តសសំខារិ-
កៈ លោភចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយទិដ្ឋិ ២ ប្រការ
ប្រកបដោយសំខារ ;

៧ - ឧបេក្ខាសហគតទិដ្ឋិគតវិប្បយុត្តអសំខារិកៈ
លោភចិត្តប្រកបដោយឧបេក្ខាវេទនា តែប្រាសចាកទិដ្ឋិ២ប្រការ មិនប្រ-
កបដោយសំខារ ;

៨ - ឧបេក្ខាសហគតទិដ្ឋិគតវិប្បយុត្តសសំខារិកៈ
លោភចិត្តប្រកបដោយឧបេក្ខាវេទនា តែប្រាសចាកទិដ្ឋិ ២ ប្រការប្រកប
ដោយសំខារ ។

## ទោសមូល ២ គឺ:

១ - ទោមនស្សសហគតបដិឃសម្បយុត្តអសំខារិ-
កៈ ទោសចិត្តប្រកបដោយទោមនស្សវេទនាព្រមដោយបដិឃៈគឺសេចក្តី
ថ្នាំងថ្នាក់ចិត្តមិនប្រកបដោយសំខារ ;

២ - ទោមនស្សសហគតបដិឃសម្បយុត្តសសំ-

www.budinst.gov.kh www.elibraryofcambodia.org

ខារឹគាៈ ទោសចិត្តប្រកបដោយទោមនស្សវេទនា ព្រមដោយបដិឃៈ គឺសេចក្តីថ្នាំងថ្នាក់ចិត្តប្រកបដោយសំខារ ។

## មោហមូល ២ គឺ:

១- ឧបេក្ខាសហគតវិចិកិច្ឆាសម្បយុត្ត មោហចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយវិចិកិច្ឆាគឺសេចក្តីសង្ស័យ;

២- ឧបេក្ខាសហគតឧទ្ធច្ចសម្បយុត្ត មោហចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយឧទ្ធច្ចគឺសេចក្តីរាយមាយ ។

## មើលភាពអកុសល ១២

| ចិត្តជាលោភមូល ៨ | | | | ទោសមូល ២ | មោហមូល ២ | |
|---|---|---|---|---|---|---|
| សោមនស្សវេទនា | | ឧបេក្ខាវេទនា | | ទោមនស្សវេទនា | ឧបេក្ខា | |
| ទិដ្ឋិគតសម្បយុត្ត | ទិដ្ឋិគតវិប្បយុត្ត | ទិដ្ឋិគតសម្បយុត្ត | ទិដ្ឋិគតវិប្បយុត្ត | បដិឃសម្បយុត្ត | វិចិកិច្ឆាសម្បយុត្ត | ឧទ្ធច្ចសម្បយុត្ត |
| អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | វិចិកិច្ឆា | ឧទ្ធច្ច |
| ២ | ២ | ២ | ២ | ២ | ១ | ១ |

www.budinst.gov.kh www.elibraryofcambodia.org

## អហេតុកចិត្ត ១៨ គឺ:

អកុសលវិបាក ៧ កុសលវិបាក ៨ អហេតុកកិរិយា ៣ ជា ១៨ ៗ

### អកុសលវិបាក ៧គឺ:

១ ២ ៣ ៤ ឧបេក្ខាសហគត ចក្ខុ សោត ឃាន ជិវ្ហា វិញ្ញាណ ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍

ក្នុង ចក្ខុ សោត ឃាន ជិវ្ហា ទ្វារ ប្រកបដោយឧបេក្ខាវេទនា;

៥. ទុក្ខសហគតកាយវិញ្ញាណ ចិត្តដឹងច្បាស់នូវអនិដ្ឋារម្មណ៍ក្នុងកាយទ្វារប្រកបដោយទុក្ខវេទនា;

៦- ឧបេក្ខាសហគតសម្បដិច្ឆន្ន ចិត្តសម្រាប់ទទួលនូវអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា;

៧- ឧបេក្ខាសហគតសន្តីរណ ចិត្តសម្រាប់ពិចារណានូវអនិដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា ។

### កុសលវិបាក ៨គឺ:

១ ២ ៣ ៤ ឧបេក្ខាសហគត ចក្ខុ សោត ឃាន ជិវ្ហា វិញ្ញាណ ចិត្តដឹងច្បាស់នូវឥដ្ឋារម្មណ៍

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| ក្នុង | ចក្ខុ<br>សោត<br>ឃាន<br>ជីវ្ហា | ទ្វារប្រកបដោយឧបេក្ខាវេទនា; |

៥- សុខសហគតកាយវិញ្ញាណ ចិត្តដឹងច្បាស់នូវឥដ្ឋារម្មណ៍ក្នុងកាយទ្វារប្រកបដោយសុខវេទនា;

៦- ឧបេក្ខាសហគតសម្បដិច្ឆន្ន ចិត្តសម្រាប់ទទួលនូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា;

៧- សោមនស្សសហគតសន្តីរណ ចិត្តសម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយសោមនស្សវេទនា;

៨- ឧបេក្ខាសហគតសន្តីរណៈ ចិត្តសម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង៥ ប្រកបដោយឧបេក្ខាវេទនា ។

គ្រង់កុសលវិបាក ទី៧ ចំណែកខាងកុសលកើតអំពីហទយវត្ថុ សម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ នឹងអតិឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រផ្ញើក្រៃពេកក្នុងទ្វារទាំង៥;

គ្រង់កុសលវិបាក ទី៨ ចំណែកខាងកុសលកើតអំពីហទយវត្ថុ សម្រាប់ពិចារណានូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង៥ តែមិនអាចនឹងពិចារណានូវអតិឥដ្ឋារម្មណ៍បានឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

## អហេតុកកិរិយា ៣ គឺ:

១- ឧបេក្ខាសហគតបញ្ចទ្វារាវជ្ជន ចិត្តសម្រាប់នឹករកនូវអារម្មណ៍ក្នុងទ្វារទាំង ៥ ប្រកបដោយឧបេក្ខាវេទនា;

២- ឧបេក្ខាសហគតមនោទ្វារាវជ្ជន ចិត្តសម្រាប់នឹករកនូវអារម្មណ៍ក្នុងមនោទ្វារប្រកបដោយឧបេក្ខាវេទនា;

៣- សោមនស្សសហគតហសិតុប្បាទ ចិត្តដែលរីករាយប្រកបដោយសោមនស្សវេទនា ។

ឯហសិតុប្បាទចិត្តនេះ កើតមានតែក្នុងសន្តានរបស់ព្រះអរិយបុគ្គល មិនដែលកើតមានក្នុងសន្តានបុថុជ្ជនឡើយ ។

អហេតុកចិត្ត ១៨ ចប់

---

## សោភណចិត្ត ៥៩ គឺ:

កាមាវចរសោភណៈ ២៤, រូបាវចរសោភណៈ ១៥, អរូបាវចរសោភណៈ ១២, លោកុត្តរសោភណៈ ៨ រួមជាសោភណចិត្ត ៥៩ សង្ខេប; បើចែកដោយពិស្តារវិញ ត្រង់លោកុត្តរចិត្តចែកចេញទៅដោយឈានជាបញ្ចកន័យ ជាចិត្ត ៤០ រួមគ្នាត្រូវជាសោភណចិត្ត ៩១ ។

## កាមាវចរសោភណ ២៤ គឺ:

សហេតុកកាមាវចរកុសល ៨, សហេតុកកាមាវចរវិបាក ៨,

www.budinst.gov.kh www.elibraryofcambodia.org

សហេតុកកាមាវចរកិរិយា ៨ ឬហៅថា មហាកុសល មហាវិបាក មហាកិរិយា ដូច្នេះវិញក៏បាន ។

## មហាកុសល ៨ គឺ:

១- សោមនស្សសហគតញ្ញាណសម្បយុត្តអសំខារិកៈ កុសលចិត្តប្រកបដោយសោមនស្សវេទនា ព្រមដោយប្រាជ្ញា មិនប្រកបដោយសំខារ;

២- សោមនស្សសហគតញ្ញាណសម្បយុត្តសសំខារិកៈ កុសលចិត្តប្រកបដោយសោមនស្សវេទនា ព្រមដោយប្រាជ្ញា ប្រកបដោយសំខារ;

៣-៤ } សោមនស្សសហគតញ្ញាណវិប្បយុត្ត { អសំខារិក / សសំខារិកៈ } កុសលចិត្ត

ប្រកបដោយសោមនស្សវេទនាតែប្រាសចាកប្រាជ្ញា { មិនប្រកបដោយសំខារ / ប្រកបដោយសំខារ };

៥-៦ } ឧបេក្ខាសហគតញ្ញាណសម្បយុត្ត { អសំខារិក / សសំខារិក } កុសល-

ចិត្តប្រកបដោយឧបេក្ខាវេទនា ព្រមដោយប្រាជ្ញា { មិនប្រកបដោយសំខារ / ប្រកបដោយសំខារ };

www.budinst.gov.kh www.elibraryofcambodia.org

៧
ឧបេក្ខាសហគតញាណវិប្បយុត្ត អសំខារិក / សសំខារិក } កុសលចិត្តប្រកប
៨

ដោយឧបេក្ខាវេទនាតែប្រាសចាកប្រាជ្ញា មិនប្រកបដោយសំខារ / ប្រកបដោយសំខារ } ។

## មើលភាពមហាកុសល-វិបាក-កិរិយា

| សោមនស្សវេទនា | | ឧបេក្ខាវេទនា | | |
|---|---|---|---|---|
| ញាណសម្បយុត្តំ | ញាណវិប្បយុត្តំ | ញាណសម្បយុត្តំ | ញាណវិប្បយុត្តំ | រួម |
| អសំខារិកំ<br>សសំខារិកំ | អសំខារិកំ<br>សសំខារិកំ | អសំខារិកំ<br>សសំខារិកំ | អសំខារិកំ<br>សសំខារិកំ | ៤<br>៤ |
| រួម ២ | រួម ២ | រួម ២ | រួម ២ | |

មហាវិបាក ៨ មហាកិរិយា ៨ ក៏មានអធិប្បាយចែកចេញទៅដូចគ្នានឹងមហាកុសលដែរ តែបើពោលដោយភូមិ ជាកាមាវចរភូមិដូចគ្នាទាំង ៣ បើពោលដោយជាតិវិញ មហាកុសលជាកុសលជាតិ មហាវិបាកនឹងមហាកិរិយាជាអព្យាក័តជាតិ ។

មហាកុសលឲ្យសម្រេចកិច្ច ៤ យ៉ាងគឺ បដិសន្ធិ ១ ភវង្គ ១ ចុតិ ១

www.budinst.gov.kh www.elibraryofcambodia.org

គទាលម្ពណា ១ នឹងជាអ្នកតាក់តែង ជាតិ ភព សម្បត្តិ ជាអ្នកដឹងនាំឲ្យកើតមហាវិបាកជាតួបដិសន្ធិ ជាអ្នកសោយនូវសម្បត្តិ ។

មហាកុសលនឹងមហាកិរិយាដូចគ្នា ឧបមាដូចតួគ្រានឹងស្នាមគ្រាដែលគេបោះចុះ ឬដូចស្រមោលក្នុងកញ្ចក់ នឹងអ្នកដែលឆ្លុះនូវកញ្ចក់នោះឯង ផ្សេងគ្នាតែទីកើត គឺមហាកុសលកើតក្នុងសន្តាននៃបុថុជ្ជន នឹងសេក្ខបុគ្គល ឯមហាកិរិយាចំពោះកើតតែក្នុងសន្តានព្រះខីណាស្រព ។

| | | |
|---|---|---|
| ក្នុងកាមាវចរចិត្ត ៥៤ នោះមាន | វិបាក | ២៣ |
| | កុសល | ៨ |
| | អកុសល | ១២ |
| | កិរិយា | ១១ |
| | រួមជា | ៥៤ |

អកុសល ១២ ជាបាប មហាកុសល ៨ ជាបុណ្យ វិបាក ២៣ នឹងកិរិយា ១១ ជាអព្យាកត ឬរាប់កាមាវចរចិត្ត ៥៤ ដូច្នេះក៏បាន

| | | |
|---|---|---|
| អកុសល | ១២ | អសោភណៈ |
| អហេតុក | ១៨ | |
| កាមាវចរសោភណ | ២៤ | |
| រួម | ៥៤ | |

**កាមាវចរចិត្ត ៥៤ ចប់**

www.budinst.gov.kh www.elibraryofcambodia.org

## មើលភាពត្រៃហេតុ នឹងទុហេតុក្នុងមហាកុសល ៨ ៖

| ទី | សោមនស្សវេទនា | ទី | ឧបេក្ខាវេទនា |
|---|---|---|---|
| ១<br>២ | ត្រៃហេតុឧក្កដ្ឋ<br>នឹងសោយវិបាក១៦ | ៥<br>៦ | ត្រៃហេតុឱមកៈ<br>នឹងសោយវិបាក១២ |
| ៣<br>៤ | ទុហេតុឧក្កដ្ឋ<br>នឹងសោយវិបាក១២ | ៧<br>៨ | ទុហេតុឱមកៈ<br>នឹងសោយវិបាក១២ |

# រូបាវចរចិត្ត

## រូបាវចរចិត្ត ១៥ គឺៈ

រូបាវចរកុសល ៥ រូបាវចរវិបាក ៥ រូបាវចរកិរិយា ៥ ។

## រូបាវចរកុសល៥គឺៈ

១- បឋមជ្ឈាន មានអង្គ ៥ គឺៈ វិតក្កៈ សភាពញុំាងចិត្តឲ្យឡើងកាន់អារម្មណ៍ ១, វិចារៈ សភាពញុំាងចិត្តឲ្យត្រាច់ទៅក្នុងអារម្មណ៍ ១, បីតិ ធម្មជាតិញុំាងកាយ នឹងចិត្តឲ្យពេញឲ្យឆ្អែតឲ្យរីករាយ ១; សុខៈ ធម្មជាតិញុំាងកាយនឹងចិត្តឲ្យតាំងនៅដោយស្រួលល្អ ១, ឯកគ្គតា ភាវៈនៃចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ១;

២- ទុតិយជ្ឈាន មានអង្គ ៤ គឺៈ វិចារៈ ១, បីតិ១, សុខៈ ១, ឯកគ្គតា១;

៣- តតិយជ្ឈានមានអង្គ ៣ គឺៈ បីតិ១, សុខៈ ១, ឯកគ្គតា១;

www.budinst.gov.kh www.elibraryofcambodia.org

៤- ចតុត្ថជ្ឈាន មានអង្គ ២ គឺ: សុខៈ១, ឯកគ្គតា១ ;

៥- បញ្ចមជ្ឈានមានអង្គ ២ គឺ ឯកគ្គតា១, ឧបេក្ខា១ ។

រូបាវចរវិបាកនឹងរូបាវចរកិរិយា ក៏ចាត់ដោយឈានបញ្ចកន័យដោយប្រាំៗដូចគ្នា ។

រូបាវចរកុសល ជាអ្នកតាក់តែងជាតិភពសម្បត្តិ ជាអ្នកដឹកនាំឲ្យបដិសន្ធិ, រូបាវចរវិបាក ជាតួបដិសន្ធិ ជាអ្នកសោយសម្បត្តិ, រូបាវចរកុសលជាកុសលជាតិរូបាវចរវិបាកនឹងរូបាវចរកិរិយាជាអព្យាកតជាតិ ។

រូបាវចរកុសលនឹងរូបាវចរកិរិយាដូចគ្នា វៀងគ្នាតែទីកើតគឺរូបាវចរកុសលកើតក្នុងសន្តានបុថុជ្ជននឹងសេក្ខបុគ្គល ឯរូបាវចរកិរិយាកើតក្នុងសន្តានព្រះខីណាស្រព ។

## មើលភាពរូបាវចរកុសល-វិបាក-កិរិយា

| | | | | | | |
|---|---|---|---|---|---|---|
| | | | អង្គ២ | ឧបេក្ខា | ឯកគ្គតា | បញ្ចមជ្ឈាន |
| | | | អង្គ ២ | សុខ | ឯកគ្គតា | ចតុត្ថជ្ឈាន |
| | | អង្គ៣ | បីតិ | សុខ | ឯកគ្គតា | តតិយជ្ឈាន |
| | អង្គ៤ | វិចារ | បីតិ | សុខ | ឯកគ្គតា | ទុតិយជ្ឈាន |
| អង្គ៥ | វិតក្ក | វិចារ | បីតិ | សុខ | ឯកគ្គតា | បឋមជ្ឈាន |

www.budinst.gov.kh www.elibraryofcambodia.org

អរូបាវចរចិត្ត

# អរូបាវចរចិត្ត ១២ គឺ:

អរូបាវចរកុសល ៤ អរូបាវចរវិបាក ៤ អរូបាវចរកិរិយា ៤ ។

## អរូបាវចរកុសល ៤ គឺ:

១- អាកាសានញ្ចាយតន យោគាវចរដែលអ្នកចំរើនឈាន យកអាកាសដែលបើកកសិណហើយមកជាអារម្មណ៍ គឺបដិភាគនិមិត្តដែលកើតពីកសិណ៩ លើកអាកាសកសិណចេញ យោគាវចរកាន់យកអាកាសដែលជារបស់ទទេមកជាអារម្មណ៍ បរិកម្មថា "អាកាសមានទីបំផុតមិនមានៗ" បរិកម្មទៅដរាបដល់អប្បនាចិត្តកើតឡើង អប្បនាចិត្តនោះលោកហៅថាបឋមារូបចិត្ត,

២- វិញ្ញាណញ្ចាយតន យោគាវចរសំដៅប្រុស្រាវយកនូវបឋមារូបចិត្តមកជាអារម្មណ៍បរិកម្មថា "វិញ្ញាណមានទីបំផុតមិនមានៗ" បរិកម្មទៅដរាបដល់អប្បនាចិត្តកើតឡើង អប្បនាចិត្តនោះលោកហៅថា ទុតិយារូបចិត្ត;

៣- អាកិញ្ចញ្ញាយតន យោគាវចរមិនបានកាន់យកនូវទុតិយារូបចិត្តមកជាអារម្មណ៍ លោកកំណត់យកនូវបឋមារូបចិត្តដែលផ្សាយនៅនោះថាបឋមារូបចិត្តដែលផ្សាយនៅក្នុងទីនេះមិនមាន ហើយយកសេចក្តីមិនមាន

www.budinst.gov.kh www.elibraryofcambodia.org

នោះមកជាអារម្មណ៍ បរិកម្មថា "វត្ថុតិចតួចមិនមាន ៗ" បរិកម្មទៅដរាប ដល់អប្បនាចិត្តកើតឡើង អប្បនាចិត្តនោះលោកហៅថា តតិយារូបចិត្ត;

៤- នេវសញ្ញានាសញ្ញាយតនៈ យោគាវចរដែលចំរើនឈានមិនបានកាន់យកនូវនត្ថិភាព គឺចំណែកដែលថាមិនមាននោះមកជាអារម្មណ៍ឡើយ លោកកំណត់យកនូវសេចក្ដីល្អិតរបស់តតិយារូបចិត្តនោះមកជាអារម្មណ៍ បរិកម្មថា "តតិយារូបចិត្តនេះ មាននៅដោយល្អិត តតិយារូបចិត្តនេះល្អិតក្រៃពេកៗ" បរិកម្មទៅដរាបដល់អប្បនាចិត្តកើតឡើងអប្បនាចិត្តនោះ លោកហៅថា ចតុត្ថារូបចិត្ត ។

ឯអរូបាវចរវិបាកនឹង អរូបាវចរកិរិយានោះ ក៏ចែកចេញទៅដូចអរូបាវចរកុសលដែរ បើពោលដោយភូមិ ក៏ជាអរូបាវចរភូមិដូចគ្នា បើពោលដោយជាតិ អរូបាវចរកុសលជាកុសលជាតិ អរូបាវចរវិបាកនឹងអរូបាវចរកិរិយាជាអព្យាកតជាតិ, អរូបាវចរកុសល ជាអ្នកតាក់តែងជាតិ [illegible] ជាអ្នកដឹកនាំឲ្យបដិសន្ធិ, អរូបាវចរវិបាកជាតួបដិសន្ធិ ជាអ្នក នុសម្បត្តិ, ឯអរូបាវចរកុសល នឹងអរូបាវចរកិរិយាដូចគ្នា ផ្សេងគ្នាតែទីកើត គឺអរូបាវចរកុសលកើតក្នុងសន្ដានបុថុជ្ជន និងសេក្ខបុគ្គល ឯអរូបាវចរកិរិយាកើតក្នុងសន្ដានព្រះខីណាស្រព ។

www.budinst.gov.kh www.elibraryofcambodia.org

## មើលភាពអរូបាវចរចិត្ត ១២ត្វ

| ឈ្មោះឈាន | កុសល | វិបាក | កិរិយា | រួមទាំង៣យ៉ាង |
|---|---|---|---|---|
| អាកាសានញ្ចាយតន | ១ | ១ | ១ | ៣ |
| វិញ្ញាណញ្ចាយតន | ១ | ១ | ១ | ៣ |
| អាកិញ្ចញ្ញាយតន | ១ | ១ | ១ | ៣ |
| នេវសញ្ញានាសញ្ញាយតន | ១ | ១ | ១ | ៣ |
| រួម | ៤ | ៤ | ៤ | ១២ |

## លោកុត្តរចិត្ត

### លោកុត្តរចិត្ត ៨ គឺៈ

១- សោតាបត្តិមគ្គចិត្ត ចិត្តដែលសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកនូវព្រះនិព្វាន នៃបុគ្គលដល់ហើយក្នុងដើមនៃធម៌ដូចជាខ្សែ ឈ្មោះជាសោតៈ;

២- សកិទាគាមិមគ្គចិត្ត ចិត្តដែលសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកនូវព្រះនិព្វាន នៃបុគ្គលដែលមកកាន់មនុស្សលោកនេះអស់វារៈមួយដោយអំណាចនៃបដិសន្ធិ;

www.budinst.gov.kh www.elibraryofcambodia.org

៣- អនាគាមិមគ្គចិត្ត ចិត្តដែលសម្បយុត្តដោយមគ្គ គឺកិរិយាស្វែងរកនូវព្រះនិព្វាន នៃបុគ្គលដែលមិនមកកាន់កាមធាតុខាងក្រោមដោយអំណាចនៃបដិសន្ធិទៀយ ;

៤- អរហត្តមគ្គចិត្ត ចិត្តដែលសម្បយុត្តដោយមគ្គគឺកិរិយាស្វែងរកនូវព្រះនិព្វាន នៃបុគ្គលមានកិរិយាធ្វើនូវបាបកម្មក្នុងទីស្ងាត់មិនមាន;

៥- សោតាបត្តិផលចិត្ត ចិត្តដែលសម្បយុត្តដោយផល គឺសេចក្តីសម្រេចនូវព្រះនិព្វាន នៃបុគ្គលដល់ហើយក្នុងដើមនៃធម៌ដូចជាខ្សែឈ្មោះថាសោតៈ ;

៦- សកិទាគាមិផលចិត្ត ចិត្តដែលសម្បយុត្តដោយផល គឺសេចក្តីសម្រេចនូវព្រះនិព្វាន នៃបុគ្គលដែលមកកាន់មនុស្សលោកនេះអស់វារៈម្តងដោយអំណាចនៃបដិសន្ធិ ;

៧- អនាគាមិផលចិត្ត ចិត្តដែលសម្បយុត្តដោយផល គឺសេចក្តីសម្រេចនូវព្រះនិព្វាន នៃបុគ្គលដែលមិនមកកាន់កាមធាតុខាងក្រោមដោយអំណាចនៃបដិសន្ធិទៀយ ;

៨- អរហត្តផលចិត្ត ចិត្តដែលសម្បយុត្តដោយផល គឺសេចក្តីសម្រេចនូវព្រះនិព្វាន នៃបុគ្គលមានកិរិយាធ្វើនូវបាបកម្មក្នុងទីស្ងាត់មិន



www.budinst.gov.kh www.elibraryofcambodia.org

លោកុត្តរចិត្ត ៨ នេះសំដែងដោយសង្ខេប, បើសំដែងដោយពិស្តារវិញ មានដល់ ៤០ គឺចែកចេញទៅដោយឈានជាបញ្ចកន័យ គឺសោតាបត្តិមគ្គចិត្ត ៥, សោតាបត្តិផលចិត្ត ៥, សកិទាគាមិមគ្គចិត្ត ៥, សកិទាគាមិផលចិត្ត ៥, អនាគាមិមគ្គចិត្ត ៥, អនាគាមិផលចិត្ត ៥, អរហត្តមគ្គចិត្ត ៥, អរហត្តផលចិត្ត ៥, រួមគ្នាទាំងអស់ត្រូវជាលោកុត្តរចិត្ត ៤០ ។

លោកុត្តរចិត្តនេះមានតែកុសលនឹងវិបាក ឯកិរិយាចិត្តមិនមាន, មគ្គចិត្តជាកុសល ផលចិត្តជាវិបាក ។

រូបាវចរចិត្ត នឹងលោកុត្តរចិត្ត លោកចែកទៅដោយឈាន ៥ បញ្ចកន័យដូចគ្នា, ប្លែកតែអរូបាវចរចិត្តទាំង ៤ នោះ លោករាប់បញ្ចូលទៅក្នុងបញ្ចមជ្ឈាន ព្រោះមានអង្គ ២ គឺ ឯកគ្គតា ១ ឧបេក្ខា ១ ដូចគ្នានឹងបញ្ចមជ្ឈាន ។

រូបាវចរជ្ឈានទាំង ៤ គឺ បឋមជ្ឈានចិត្ត ១, ទុតិយជ្ឈានចិត្ត ១, តតិយជ្ឈានចិត្ត ១, ចតុត្ថជ្ឈានចិត្ត ១, បួនឈាននេះ ក្នុងឈានមួយ ៗ រាប់ចិត្តបាន ១១ ៗ គ្រប់ឈានទាំង ៤, ឯបញ្ចមជ្ឈានចិត្តរាប់ចិត្តបាន ២៣ ។

ឈានចិត្ត ១១ នោះគឺ រូបាវចរ ៣ ដែលជាកុសល ១ វិបាក ១ កិរិយា ១ នឹងលោកុត្តរ ៨ ដែលជាមគ្គចិត្ត ៤ ផលចិត្ត ៤ រួមជា ១១, បញ្ចមជ្ឈានចិត្ត ២៣ គឺរូបាវចរបញ្ចមជ្ឈាន ៣ អរូបាវចរបញ្ចមជ្ឈាន ១២ លោកុត្តរបញ្ចមជ្ឈាន ៨ ជា ២៣ ។

www.budinst.gov.kh www.elibraryofcambodia.org

រួមចិត្តសង្ខេបបញ្ចូលគ្នាទាំង ៤ ភូមិ គឺអកុសលចិត្ត ១២ ដែលជាលោភមូល ៨ ទោសមូល ២ មោហមូល ២ ជា ១២, កុសល ២១ គឺមហាកុសល ៨ រូបាវចរកុសល ៥ អរូបាវចរកុសល ៤ លោកុត្តរកុសល ៤ ជា ២១, វិបាកចិត្ត ៣៦ គឺអហេតុកវិបាក ១៥ មហាវិបាក ៨ មហគ្គតវិបាក ៩ លោកុត្តរវិបាក ៤ ជា ៣៦, កិរិយាចិត្ត ២០ គឺអហេតុកកិរិយា ៣ មហាកិរិយា ៨ មហគ្គតកិរិយា ៩ ជា ២០ ។

ចាត់ចិត្តតាមភូមិ ៤ គឺ កាមាវចរភូមិ ៥៤ រូបាវចរភូមិ ១៥ អរូបាវចរភូមិ ១២ លោកុត្តរភូមិ ៨ បូករួមជាចិត្ត ៨៩ ដោយសង្ខេប ។

ចិត្តពិស្តារ ១២១ គឺកុសលចិត្ត ៣៧ ដែលជាមហាកុសល ៨ មហគ្គតកុសល ៩ លោកុត្តរកុសល ២០ ជា ៣៧, វិបាកចិត្ត ៥២ ដែលជាកាមាវចរវិបាក ២៣ មហគ្គតវិបាក ៩ លោកុត្តរវិបាក ២០ ជា ៥២, យកអកុសលចិត្ត ១២ នឹងកិរិយាចិត្ត ២០ បូកបញ្ចូលផងត្រូវជាចិត្ត ១២១ ។

ចិត្តសង្ខេប ៨៩ នោះរាប់ជា ១ យកចេតសិក ៥២ នឹងនិប្ផន្នរូប ១៨ នឹងទុក្ខ ៤ គឺជាតិ ជរា ព្យាធិ មរណៈ បូកជា ៧៥ ចាត់ជានាមធម៌ខាងក្នុង ៧៥ រូបធម៌ខាងក្រៅ ៧៥ រួមជា ១៥០ យកកិលេស ១០ មកគុណ ជា ១៥០០ ។

www.budinst.gov.kh www.elibraryofcambodia.org

# មើលភាពចិត្តបរមត្ថ

| ឈ្មោះចិត្ត | កុសលាធម្មា | អកុសលាធម្មា | | | អព្យាកតាធម្មា | | រួម |
|---|---|---|---|---|---|---|---|
| | ចិត្តកុសល | លោភ | ទោស | មោហ | វិបាក | កិរិយា | |
| កាមាវចរ | ៨ | ៨ | ២ | ២ | ២៣ | ១១ | ៥៤ |
| រូបាវចរ | ៥ | ០ | ០ | ០ | ៥ | ៥ | ១៥ |
| អរូបាវចរ | ៤ | ០ | ០ | ០ | ៤ | ៤ | |
| លោកុត្តរ | ២០ | ០ | ០ | ០ | ២០ | | |
| រួម | ៣៧ | ៨ | ២ | ២ | ៥២ | ២០ | ១២១ |

ចប់ប្រភេទទី ១

## ប្រភេទទី ២ ពោលអំពីចេតសិក

## ចេតសិក

ធម៌៥២ ដែលប្រកបនឹងចិត្តដោយហេតុ ៤ យ៉ាងគឺ:

១- ឯកុប្បាទៈ ចិត្តកើតក្នុងខណៈណា ចេតសិកក៏កើតក្នុងខណៈនោះជាមួយគ្នា ;

២- ឯកនិរោធៈ ចិត្តរលត់ទៅក្នុងខណៈណា ចេតសិកក៏រលត់ទៅក្នុងខណៈនោះជាមួយគ្នា ;

www.budinst.gov.kh www.elibraryofcambodia.org

៣- ឯកាលម្ពណៈ ចិត្តកើតក្នុងអារម្មណ៍ណា ចេតសិកក៏កើតក្នុងអារម្មនោះជាមួយគ្នា ;

៤- ឯកវត្ថុកៈ ចិត្តសំរេជាយកវត្ថុណាជាអារម្មណ៍ ចេតសិកក៏សំរេជាយកវត្ថុនោះជាអារម្មណ៍ដូចគ្នា ។

ធម៌ដែលប្រកបជុំនឹងចិត្តដោយហេតុ ៤ យ៉ាងនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ហៅថា ចេតសិក ។

## ចេតសិកមាន ៥២ គឺៈ

អញ្ញសមានាចេតសិក ១៣, អកុសលចេតសិក ១៤, សោភណចេតសិក ២៥ ។

អញ្ញសមានាចេតសិក ១៣ នោះចែកចេញជា ២ពួកគឺសព្វចិត្តសាធារណចេតសិក ៧, បកិណ្ណកចេតសិក ៦ ត្រូវជា ១៣ ។

## សព្វចិត្តសាធារណចេតសិក៧នោះគឺៈ

១- ផស្សៈ សភាពជាអ្នកផ្ទួននូវអារម្មណ៍ទាំង៦ ឲ្យពាល់ត្រូវទ្វារទាំង៦ ;

២- វេទនា ធម្មជាតិដឹងនូវអារម្មណ៍ឬសោយនូវអារម្មណ៍ ;

៣- សញ្ញា ធម្មជាតិចាំនូវអារម្មណ៍ ឬកត់នូវអារម្មណ៍ ;

៤- ចេតនា ធម្មជាតិគិតដឹកនាំចិត្ត ឬធម្មជាតិសន្សំនូវបុណ្យនឹងបាប ;

www.budinst.gov.kh www.elibraryofcambodia.org

៥- ឯកគ្គតា ភាវៈផ្តុំចិត្តឲ្យមានអារម្មណ៍តែមួយ ;

៦- ជីវិតិន្ទ្រិយ: ឥន្ទ្រិយគឺជីវិតជាធម្មជាតិញុំាងសហជាតធម៌ឲ្យរស់នៅ;

៧- មនសិការ: សេចក្តីធ្វើទុកក្នុងចិត្ត ។

## បកិណ្ណកចេតសិក ៦ គឺ:

១- វិតក្កោ សភាពធ្វើចិត្តឲ្យឡើងកាន់អារម្មណ៍ ឬឲ្យត្រិះរិះនូវអារម្មណ៍ ;

២- វិចារោ សភាពពិចារណានូវអារម្មណ៍ ឬញុំាងចិត្តឲ្យត្រាច់នៅក្នុងអារម្មណ៍ ;

៣- អធិមោក្ខោ សភាពធ្វើឲ្យតាំងចុះវិណានក្នុងអារម្មណ៍ ;

៤- វិរិយំ ធម្មជាតឧបត្ថម្ភនាំទ្រចិត្តមិនឲ្យរួញរា ;

៥- បីតិ ធម្មជាតិធ្វើកាយនឹងចិត្តឲ្យឆ្អែត ;

៦- ឆន្ទោ សភាពធ្វើចិត្តឲ្យប្រាថ្នានូវអារម្មណ៍ ។

## អកុសលចេតសិក ១៤ គឺ:

១- មោហោ សភាពធ្វើចិត្តឲ្យវង្វេងក្នុងអារម្មណ៍ ;

២- អហិរិកំ ធម្មជាតមិនខ្មាសអំពើទុច្ចរិត ;

៣- អនោត្តប្បំ ធម្មជាតមិនស្ញុតខ្លាចអំពើទុច្ចរិត ;

៤- ឧទ្ធច្ចំ ធម្មជាតធ្វើចិត្តឲ្យញាប់ញ័រឬឲ្យរាយមាយ ;

www.budinst.gov.kh www.elibraryofcambodia.org

៥- លោភោ សភាពធ្វើចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍ ;

៦- ទិដ្ឋិ ធម្មជាតិធ្វើចិត្តឲ្យឃើញខុសឬឲ្យយល់ខុស ;

៧- មានោ សភាពលើកខ្លួនឲ្យខ្ពស់ឬឲ្យប្រសើរជាងគេ ;

៨- ទោសោ សភាពទ្រុស្តក្នុងអារម្មណ៍ ឬប្រទុស្ត ;

៩- ឥស្សា ធម្មជាតិច្រណែននូវសម្បត្តិនៃអ្នកដទៃ ;

១០- មច្ឆរិយំ ធម្មជាតិលាក់លៀមនូវសម្បត្តិ(សេចក្តីកំណាញ់);

១១- កុក្កុច្ចំ ធម្មជាតិធ្វើចិត្តឲ្យស្តួសទោរដោយការដែលខ្លួនប្រ-ព្រឹត្តខុស ប្រព្រឹត្តកន្លង ;

១២- ថីនំ ធម្មជាតិធ្វើចិត្តឲ្យរួញរា មិនឲ្យខ្វល់ខ្វាយ ;

១៣- មិទ្ធំ ធម្មជាតធ្វើឲ្យងងុយ ឲ្យងោក ឲ្យលក់ ;

១៤- វិចិកិច្ឆា ធម្មជាតិធ្វើចិត្តឲ្យសង្ស័យឬឲ្យស្ទាក់ស្ទើរ ។

## សោភណចេតសិក ២៥ គឺ:

សោភណសាធារណៈ ១៩, វិរតិ៣, អប្បមញ្ញា២, បញ្ញិន្ទ្រិយ១ ។

## សោភណសាធារណ ១៩ គឺ:

១- សទ្ធា ធម្មជាតិជឿកម្មនឹងផលនៃកម្ម ;

២- សតិ ធម្មជាតិធ្វើចិត្តឲ្យរលឹក ;

៣- ហិរិ ធម្មជាតិខ្មាស់បាបទើមអំពើទុច្ចរិត ;

www.budinst.gov.kh www.elibraryofcambodia.org

៤- ឧត្តប្បៈ ធម្មជាតិស្លុតខ្លាចអំពើទុច្ចរិត ;

៥- អលោភោ សភាពមិនរវៀចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍;

៦- អទោសោ សភាពមិនប្រទុស្ត ;

៧- តត្រមជ្ឈត្តតា ភាវៈប្រនើយកន្តើយក្នុងសត្វនិងសង្ខារ ;

៨- កាយបស្សទ្ធិ សេចក្តីរម្ងាប់កាយ ;

៩- ចិត្តបស្សទ្ធិ សេចក្តីរម្ងាប់ចិត្ត ;

១០- កាយលហុតា ភាវៈនៃកាយដ៏ស្រាលេ ;

១១- ចិត្តលហុតា ភាវៈនៃចិត្តដ៏ស្រាល ;

១២- កាយមុទុតា ភាវៈនៃកាយដ៏ទន់ ;

១៣- ចិត្តមុទុតា ភាវៈនៃចិត្តដ៏ទន់ ;

១៤- កាយកម្មញ្ញតា ភាវៈនៃកាយដ៏គួរដល់ការងារ ;

១៥- ចិត្តកម្មញ្ញតា ភាវៈនៃចិត្តដ៏គួរដល់ការងារ ;

១៦- កាយបាគុញ្ញតា ភាវៈនៃកាយដ៏ស្ទាត់ជំនាញ ;

១៧- ចិត្តបាគុញ្ញតា ភាវៈនៃចិត្តដ៏ស្ទាត់ជំនាញ ;

១៨- កាយុជុកតា ភាវៈនៃកាយដ៏ត្រង់ ;

១៩- ចិត្តុជុកតា ភាវៈនៃចិត្តដ៏ត្រង់ ។

វិរតិចេតសិក ៣ គឺ:

២០- សម្មាវាចា ចេតនាជាហេតុវៀរពាលស្តួរវៀរចាកវចីទុច្ចរិត ;

www.budinst.gov.kh www.elibraryofcambodia.org

២១- សម្មាកម្មន្តោ ការងារល្អវៀរចាកកាយទុច្ចរិត ;

២២- សម្មាអាជីវោ ចិញ្ចឹមជីវិតល្អវៀរចាកជំនួញ៥ប្រការ ។

## អប្បមញ្ញា ២គឺ:

២៣- ករុណា សេចក្តីអាណិតប្រុងនឹងដោះទុក្ខសត្វឲ្យរួចចាក

ទុក្ខ ;

២៤- មុទិតា សេចក្តីបន្ទន់ចិត្តទៅក្នុងសម្បត្តិនៃបុគ្គលដទៃ ;

២៥- បញ្ញិន្ទ្រិយ បញ្ញាជាធំជាងសហជាតធម៌ទាំងពួង ។

សោភណចេតសិក ២៥ ចប់

## សម្បយោគ

ការប្រកបចេតសិកចូលក្នុងចិត្តហៅថាសម្បយោគៗ នោះមាន៤ពួក

បើចែកចេញជាន័យមាន១៦គឺ :

ពួកទី១ សព្វចិត្តសាធារណចេតសិក៧ប្រកបចូលក្នុងចិត្តទាំងអស់១ន័យ;

ពួកទី២ បកិណ្ណកចេតសិក៦ ប្រកបចូលក្នុងចិត្តដែលគួរប្រកប៦ន័យ;

ពួកទី៣ អកុសលចេតសិក១៤ប្រកបចូលក្នុងចិត្តអកុសលដប់ពីរ៥ន័យ;

ពួកទី៤ សោភណចេតសិក២៥ ប្រកបចូលក្នុងចិត្ត៥៩ឬ៩១ បួនន័យ ។

រួមជា៤ពួកនឹង១៦ន័យ

## សំដែងសម្បយោគ១៦ន័យ

១-សព្វចិត្តសាធារណ ៧ ប្រកបចូលក្នុងចិត្តទាំងអស់មិនមានវៀរ ១

www.budumst.gov.kh www.elibraryofcambodia.org

## ២- បកិណ្ណកចេតសិក៦នោះគឺ:

(១) វិតក្កៈកើតក្នុងចិត្ត ៥៥ គឺ:

- សម្បដិច្ឆន្ន ២;
- សន្តីរណា ៣;
- អហេតុកកិរិយា ៣;
- អកុសល ១២
- កាមាវចរសោភណ ២៤;
- បឋមជ្ឈាន ១១
- រួមជា ៥៥

(២) វិចារៈកើតក្នុងចិត្ត ៦៦ គឺ:

- សម្បដិច្ឆន្ន ២;
- សន្តីរណា ៣;
- អហេតុកកិរិយា ៣;
- អកុសល ១២;
- កាមាវចរសោភណ ២៤
- បឋមជ្ឈាន ១១;
- ទុតិយជ្ឈាន ១១;

រួមជា ៦៦

(៣) អធិមោក្ខៈកើតក្នុងចិត្ត៧៨ គឺចិត្ត៨៩

- វៀរទ្វិបញ្ចវិញ្ញាណ១០
- នឹងបឋមជ្ឈាន១

នៅសល់ ៧៨ ។

(៤) វីរិយៈកើតក្នុងចិត្ត៧៣ គឺចិត្ត៨៩វៀរ

- បញ្ចទ្វារាវជ្ជន១;
- ទ្វិបញ្ចវិញ្ញាណ១០
- សម្បដិច្ឆន្ន២;
- សន្តីរណា៣;

នៅសល់ ៧៣ ។

www.budinst.gov.kh www.elibraryofcambodia.org

(៥) បីតិកើតក្នុងចិត្ត ៥១ គឺ
- កាមសោមនស្ស ១៨;
- បឋមជ្ឈាន ១១;
- ទុតិយជ្ឈាន ១១;
- តតិយជ្ឈាន ១១ ។

វៀរ
- ទោមនស្ស ២;
- ឧបេក្ខា ៥៥;
- កាយវិញ្ញាណ ២;
- ចតុត្ថជ្ឈាន ១១ ។

រួមជា ៥១ ។

(៦) ឆន្ទកើតក្នុងចិត្ត ៦៩ គឺ
- លោភមូល ៨;
- ទោសមូល ២;
- កាមាវចរសោភណ ២៤;
- មហគ្គតចិត្ត ២៧;
- លោកុត្តរ ៨ ។

វៀរ
- អហេតុក ១៨;
- មោហ ២ ។

សព្វចិត្តសាធារណចេតសិក ៧ នឹងបកិណ្ណកចេតសិក ៦ រួមគ្នាបេរ៉េ អញ្ញសមានាចេតសិក ។ នោះមាន ១៣ ប្រកបចូលនឹងចិត្ត ៧ ... ...យោគ ៧ នយ ។

ចប់សម្បយោគអញ្ញសមានាចេតសិក ៧ នយ ។

អកុសលចេតសិក ១៤ ប្រកបចូលនឹងចិត្តអកុសល ១២ នោះគឺ:

១- មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ចេតសិក ៤ នេះហៅថាអកុសលសាធារណប្រកបចូលនឹង អកុសលចិត្ត ១២;

២- លោភៈ ទិដ្ឋិ មានៈ ចេតសិក ៣ នេះប្រកបចូលនឹងចិត្តជាលោភមូល ៨ តែទិដ្ឋិ ប្រកបចូលនឹងចិត្តជាសម្បយុត្ត ៤ មានៈប្រកបចូលនឹងចិត្ត ជាវិប្បយុត្ត ៤

www.budinst.gov.kh www.elibraryofcambodia.org

៣- ទោស
ឥស្សា
មច្ឆរិយ
កុក្កុច្ច } ចេតសិក ៤ នេះប្រកបចូលនឹងចិត្តជាទោសមូល ២;

៤- ថីន
មិទ្ធ } ចេតសិក ២ នេះប្រកបចូលនឹងចិត្តជាសសំខារិកទាំង ៥;

៥- វិចិកិច្ឆា ចេតសិក ១ នេះប្រកបចូលនឹងចិត្តជាវិចិកិច្ឆា ;

ចប់អកុសលចេតសិក ៥នយ

សោភណចេតសិក ២៥ ប្រកបចូលនឹងចិត្តដូចតទៅនេះ

១- សោភណសាធារណចេតសិក ១៩ ប្រកបចូលនឹងចិត្តជាសោភណ

៥៩ ឬ ៩១

២- វិរតិចេតសិក ៣ ប្រកបចូលនឹងចិត្តជា { មហាកុសល ៨
លោកុត្តរ ៨ } រួមជា ១៦

៣- អប្បមញ្ញាចេតសិកកើតក្នុងចិត្ត ២៨ គឺ { កាមាវចរកុសល ៨;
កាមាវចរកិរិយា ៨;
បឋមជ្ឈាន ៣;
ទុតិយជ្ឈាន ៣;
តតិយជ្ឈាន ៣;
ចតុត្ថជ្ឈាន ៣;
រួមជា ២៨ ។

៤- បញ្ញាចេតសិក ១ កើតក្នុងចិត្ត ៤៧ គឺ { កាមាវចរញាណសម្បយុត្ត ១២;
មហគ្គត ២៧;
លោកុត្តរៈ ៨ ។
រួមជា ៤៧ ។

ចប់សម្បយោគសោភណចេតសិក ៤ នយ ។

www.budinst.gov.kh www.elibraryofcambodia.org

រួមសម្បយោគទាំងអស់១+៦+៥+៤=១៦ន័យ ។

# យោគីចេតសិក

## យោគីចេតសិកមាន ២ គឺៈ

១- អនិយតយោគីចេតសិក ចេតសិកដែលកើតក្នុងចិត្ត មិនទៀងជួនណាក៏កើតជាមួយគ្នា ជួនណាក៏កើតផ្សេងពីគ្នា, ចេតសិកនេះ មាន ១១ គឺ ឥស្សា ១, មច្ឆរិយ ១, កុក្កុច្ច ១, សម្មាវាចា ១, សម្មាកម្មន្ត ១, សម្មាអាជីវ ១, ករុណា ១, មុទិតា ១, មាន ១, ថីន ១, មិទ្ធ ១ ។

២- និយតយោគីចេតសិក ចេតសិកដែលកើតក្នុងចិត្តទៀង, ចេតសិកនេះមាន ៤១ គឺ ចេតសិក ៥២ វៀរលែងអនិយតយោគីចេតសិក ១១ចេញនៅសល់ ៤១ ។

ចប់យោគីចេតសិក

# សង្គហ

សង្គហមាន ៥ ចែកចេញជា ៣៣ ន័យគឺ:

១- អនុត្តរសង្គហ បានដល់ចិត្តជាលោកុត្តរ ៨ មាន ៥ ន័យ,

២- មហគ្គតសង្គហ បានដល់ចិត្តជាមហគ្គត ២៧ មាន ៥ ន័យ

៣- សោភណសង្គហ បានដល់ចិត្តជាកាមាវចរ ២៤ មាន ១២ ន័យ

៤- អកុសលសង្គហ បានដល់ចិត្តជាអកុសល ១២ មាន ៧ន័យ

www.budinst.gov.kh www.elibraryofcambodia.org

៥- អហេតុកសង្គហ បានដល់ចិត្តជាអហេតុក ១៨ មាន ៤ ន័យ

រួមចិត្ត ៨៩, សង្គហ ៣៣ន័យ

## អនុត្តរសង្គហ ៥ ន័យគឺៈ

១- បឋមជ្ឈាន {មគ្គ ៤, ផល ៤} ជា៨មានចេតសិកប្រកប ៣៦

គឺ {
អញ្ញសមានា ១៣
សោភណ ២៣ វៀរ
អប្បមញ្ញា ២;
}

២- ទុតិយជ្ឈាន {មគ្គ ៤, ផល ៤} ជា ៨ មានចេតសិកប្រកប ៣៥

គឺ {
អញ្ញសមានា ១២ វៀរវិតក្ក ;
សោភណ ២៣ វៀរ
អប្បមញ្ញា ២ ;
}

៣- តតិយជ្ឈាន {មគ្គ ៤, ផល៤} ជា៨មានចេតសិកប្រកប ៣៤

គឺ {
អញ្ញសមានា ១១
វៀរវិតក្កនឹងវិចារៈ ;
សោភណ ២៣
វៀរអប្បមញ្ញា ២ ;
}

៤- ចតុត្ថជ្ឈាន {មគ្គ ៤, ផល៤} ជា៨ មានចេតសិកប្រកប ៣៣

គឺ {
អញ្ញសមានា ១០
វៀរវិតក្កវិចារបីតិ
សោភណ ២៣
វៀរអប្បមញ្ញា២;
}

LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

៥- បញ្ចមជ្ឈាន {មគ្គ ៤ / ផល ៤} ជា៨ មានចេតសិកប្រកប ៣៣

គឺ {អញ្ញសមានា ១០ / វៀរវិតក្កវិចារបីតិ ; / សោភណា ២៣ / វៀរអប្បមញ្ញា ២ ;

ចប់អនុត្តរសង្គហា

## មហគ្គតសង្គហ ៥ន័យគឺ

១- បឋមជ្ឈាន៣ គឺ {កុសល១ / វិបាក១ / កិរិយា ១} មានចេតសិកប្រកប៣៥គឺ {អញ្ញសមានា ១៣ ; / សោភណា២២ ; / វៀរវិរតិ៣ ;

២- ទុតិយជ្ឈាន ៣គឺ {កុសល ១ / វិបាក១ / កិរិយា១} មានចេតសិកប្រកប ៣៤

គឺ {អញ្ញសមានា ១២ ; / វៀរវិតក្ក១ ; / សោភណា២២ / វៀរវិរតិ ៣ ;

៣- តតិយជ្ឈាន៣គឺ {កុសល ១ / វិបាក ១ / កិរិយា ១} មានចេតសិកប្រកប ៣៣

គឺ {អញ្ញសមានា១១ / វៀរវិតក្ក១វិចារ១ ; / សោភណា ២២ / វៀរវិរតិ ៣ ;

www.budhist.gov.kh www.elibraryofcambodia.org

៤- ចតុត្ថជ្ឈាន ៣ គឺ { កុសល ១ / វិបាក ១ / កិរិយា ១ } មានចេតសិកប្រកប ៣២ គឺ { អញ្ញសមានា ១០ វៀរវិតក្កវិចារបីតិ ; សោភណ ២២ វៀរវិរតិ ៣ ;

៥- { បញ្ចមជ្ឈាន ៣ / អរូបជ្ឈាន ១២ } ជា ១៥ មានចេតសិកប្រកប ៣០ គឺ { អញ្ញសមានា ១០ វៀរវិតក្កវិចារបីតិ ; សោភណ ២០ វៀរវិរតិ ៣ អប្បមញ្ញា ២ ;

ចប់មហគ្គតសង្គហ

## សោភណសង្គហ ១២ន័យគឺ:

កុសល ៤ វិបាក ៤ កិរិយា ៤ តែលោកចាត់ជាទុក្កៈគឺជាគូៗ ដូចគ្នាទាំងអស់

## កុសល ៤ គឺ

១- បឋមទុក្កៈបានដល់ចិត្តទី ១-២ មានចេតសិកប្រកប ៣៨ គឺ { អញ្ញសមានា ១៣ / សោភណ ២៥

២- ទុតិយទុក្កៈ បានដល់ចិត្តទី ៣-៤ មានចេតសិកប្រកប ៣៧ គឺ { អញ្ញសមានា ១៣ ; សោភណ ២៤ វៀរបញ្ញា ;

៣- តតិយទុក្កៈ បានដល់ចិត្តទី ៥-៦ មានចេតសិកប្រកប ៣៧ គឺ { អញ្ញសមានា ១២ វៀរបីតិ ; សោភណ ២៥ ;

៤- ចតុត្ថទុក្កៈ បានដល់ចិត្តទី ៧-៨ មានចេតសិកប្រកប ៣៦ គឺ { អញ្ញសមានា ១២ វៀរបីតិ ; សោភណ ២៤ វៀរបញ្ញា ;

www.budinst.gov.kh www.elibraryofcambodia.org

# វិបាក ៤ គឺ

១- បឋមទុក្កៈបានដល់ចិត្តទី ១-២ មានចេតសិកប្រកប ៣៣ គឺ
- អញ្ញសមានា ១៣;
- សោភណ ២០
- វៀរវិរតិ ៣ អប្បមញ្ញា ២;

២- ទុតិយទុក្កៈបានដល់ចិត្តទី ៣-៤ មានចេតសិកប្រកប ៣២ គឺ
- អញ្ញសមានា ១៣;
- សោភណ ១៩
- វៀរវិរតិ ៣
- អប្បមញ្ញា ២
- បញ្ញា ១;

៣- តតិយទុក្កៈ បានដល់ចិត្ត ៥-៦ មានចេតសិកប្រកប ៣២ គឺ
- អញ្ញសមានា ១២ វៀរបីតិ;
- សោភណ ២០ វៀរវិរតិ ៣
- អប្បមញ្ញា ២;

៤- ចតុត្ថទុក្កៈ បានដល់ចិត្តទី ៧-៨ មានចេតសិកប្រកប ៣១ គឺ
- អញ្ញសមានា ១២
- វៀរបីតិ;
- សោភណ ១៩ វៀរវិរតិ ៣
- អប្បមញ្ញា ២ បញ្ញា ១;

www.budinst.gov.kh www.elibraryofcambodia.org

# កិរិយា ៤ គឺៈ

១- បឋមឆក្កៈ បានដល់ចិត្តទី១-២ មានចេតសិកប្រកប ៣៥

គឺ
- អញ្ញសមានា ១៣ ;
- សោភណ២២
- វៀរវិរតិ ៣ ;

២- ទុតិយឆក្កៈ បានដល់ចិត្តទី៣-៤ មានចេតសិកប្រកប ៣៤

គឺ
- អញ្ញសមានា ១៣ ;
- សោភណ២១ វៀរវិរតិ៣
- បញ្ញា ១ ;

៣- តតិយឆក្កៈ បានដល់ចិត្តទី ៥-៦ មានចេតសិកប្រកប

៣៤ គឺ
- អញ្ញសមានា ១២
- វៀរបីតិ ;
- សោភណ ២២វៀរវិរតិ៣ ;

៤- ចតុត្ថឆក្កៈ បានដល់ចិត្តទី៧-៨ មានចេតសិកប្រកប ៣៣

គឺ
- អញ្ញសមានា១២
- វៀរបីតិ ;
- សោភណ២១វៀរវិរតិ៣
- បញ្ញា១ ;

ចប់សោភណសង្គហ ១២ន័យ

## អកុសលសង្គហ៧ ន័យគឺៈ

លោភមូល ៨ មាន ៤ ន័យ ទោសមូល ២ មាន២ន័យ មោហមូល២

មាន ១ ន័យជា ៧ ន័យ ។

www.budinst.gov.kh www.elibraryofcambodia.org

# លោភមូល ៨ មាន ៤ ន័យគឺ

១
- អសំខារិកទី១ គឺចិត្តទី ១ មានចេតសិកចុះ ១៩ គឺ
  - អញ្ញសមានា ១៣,
  - អកុសលសាធារណ ៤ ខាងដើម
  - លោភ ១ ទិដ្ឋិ ១ ;
- អសំខារិកទី២ គឺចិត្តទី ៣ មានចេតសិកចុះ ១៩ គឺ
  - អញ្ញសមានា ១៣ ;
  - អកុសលសាធារណ ៤
  - លោភ ១ មាន ១

២
- អសំខារិកទី ៣ គឺចិត្តទី ៥ មានចេតសិកចុះ ១៨ គឺ
  - អញ្ញសមានា ១២ វៀរបីតិ ១,
  - អកុសលសាធារណ ៤
  - លោភ ១ ទិដ្ឋិ ១ ;
- អសំខារិកទី ៤ គឺចិត្តទី ៧ មានចេតសិកចុះ ១៨ គឺ
  - អញ្ញសមានា ១២ វៀរបីតិ ១,
  - អកុសលសាធារណ ៤
  - លោភ ១ មាន ១ ;

៣
- សសំខារិកទី ១ គឺចិត្តទី ២ មានចេតសិកចុះ ២១ គឺ
  - អញ្ញសមានា ១៣,
  - អកុសលសាធារណ ៤ លោភ ១
  - ទិដ្ឋ ១ ថីន ១ មិទ្ធ ១,
- សសំខារិកទី ១ គឺចិត្តទី ៤ មានចេតសិកចុះ ២១ គឺ
  - អញ្ញសមានា ១៣,
  - អកុសលសាធារណ ៤ លោភ ១
  - មាន ១ ថីន ១ មិទ្ធ ១ ;

៤
- សសំខារិកទី ៣ គឺចិត្តទី ៦ មានចេតសិកចុះ ២០ គឺ
  - អញ្ញសមានា ១២ វៀរបីតិ ១ ;
  - អកុសលសាធារណ ៤ ;
  - លោភ ១ ទិដ្ឋិ ១ ថីន ១ មិទ្ធ ១ ;
- សសំខារិកទី ៤ គឺចិត្តទី ៨ មានចេតសិកចុះ ២០ គឺ
  - អញ្ញសមានា ១២ វៀរបីតិ ១ ;
  - អកុសលសាធារណ ១ ;
  - លោភ ១ មាន ១ ថីន ១ មិទ្ធ ១ ;

www.budinst.gov.kh www.elibraryofcambodia.org

## ទោសមូល ២ មាន ២ ន័យគឺ

៥-អសំខារិកទី៥ គឺចិត្តទី ១ មានចេតសិកចុះ ២០ គឺ { អញ្ញសមានា១៣ អកុសលសាធារណ ឥស្សា ១ មច្ឆរិយ

៦-សសំខារិកទី៥ គឺចិត្ត ២ មានចេតសិកចុះ ២២ គឺ { អញ្ញសមានា ១២វៀរប៉ី អកុសលសាធារណ៤ ទោស១ ឥស្សា១ មច្ឆរិយ១ កុក្កុច្ច១ ថីន១ មិទ្ធ១;

## មោហមូល ២ មាន ១ ន័យគឺ:

៧ {
ឧទ្ធច្ចគឺចិត្តទី ១ មានចេតសិកចុះ ១៥ គឺ { អញ្ញសមានា១១វៀរបីតិ១ ឆន្ទ១; អកុសលសាធារណ៤;

វិចិកិច្ឆាគឺចិត្តទី ២ មានចេតសិកចុះ ១៥ គឺ { អញ្ញសមានា១១វៀរបីតិ១ អធិមោក្ខ១; អកុសលសាធារណ៣ គឺមោហ១ អហិរិក១ អនោត្តប្ប១ រួមវិចិកិច្ឆា១;
}

ចប់អកុសលសង្គហ ៧ ន័យ

---

## អហេតុកសង្គហ ៤ ន័យគឺ

១- ទ្វិបញ្ចវិញ្ញាណ ១០ គឺ { កុសលវិបាក ៥ អកុសលវិបាក ៥ } មានចេតសិកចុះគឺសព្វចិត្តសាធារណទាំង ៧;

២-ហសិតុប្បាទ មានចេតសិកចុះ ១២ គឺ អញ្ញសមានា ១២ វៀរឆន្ទ១;

៣- { សុខសន្តីរណ មានចេតសិកចុះ ១១ គឺអញ្ញសមានា ១១ វៀរឆន្ទ១វិរិយ១; មនោទ្វារាវជ្ជន មានចេតសិកចុះ ១១ គឺអញ្ញសមានា ១១ វៀរឆន្ទ១បីតិ១;

www.budinst.gov.kh www.elibraryofcambodia.org

៤-មនោធាតុ៣គឺ { បញ្ចទ្វារាវជ្ជន១ / អកុសលសម្បដិច្ឆន្ន១ / កុសលសម្បដិច្ឆន្ន១ } នឹងឧបេក្ខាសន្តីរណ២មានចេតសិកចុះ ១០គឺអញ្ញសមានា១០វៀរឆន្ទបីតិវិរិយ

ចប់អហេតុកសង្គហ ៤នយ

ចប់សង្គហ ៥ ពួក ៣៣នយ

ភូមិនឹងប្រភេទបុគ្គលដែលអាស្រ័យនៅក្នុងភូមិ ព្រមទាំងប្រភេទចិត្ត របស់បុគ្គល ។

## ភូមិ

ភូមិមាន ៤គឺ
- ១- អបាយភូមិ ;
- ២- កាមភូមិ ;
- ៣- រូបភូមិ ;
- ៤- អរូបភូមិ ;

អបាយភូមិមាន៤គឺ
- ១- នរក ;
- ២- ប្រេត ;
- ៣- តិរច្ឆាន ;
- ៤- អសុរកាយ ។

កាមភូមិមាន៧គឺ
- ១- មនុស្ស ;
- ២- ចាតុម្មហារាជិកា ;
- ៣- តាវតិំសា ;
- ៤- យាមា ;
- ៥- តុសិតា ;
- ៦- និម្មានរតី ;
- ៧- បរនិម្មិតវសវត្តី ; ។

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| រូបភូមិមាន១៦គឺ | ១- ព្រហ្មបារិសជ្ជា | បឋមជ្ឈានភូមិ៣ ; |
| | ២- ព្រហ្មបុរោហិតា | |
| | ៣- មហាព្រហ្ម | |
| | ៤- បរិត្តាភា | ទុតិយជ្ឈានភូមិ៣ ; |
| | ៥- អប្បមាណាភា | |
| | ៦- អាភស្សរា | |
| | ៧- បរិត្តសុភា | តតិយជ្ឈានភូមិ៣ ; |
| | ៨- អប្បមាណសុភា | |
| | ៩- សុភកិណ្ហា | |
| | ១០- វេហប្ផលា | ចតុត្ថជ្ឈានភូមិ ២របស់បុថុជ្ជន ; |
| | ១១- អសញ្ញិសត្តា | |
| | ១២- អវិហា | ចតុត្ថជ្ឈានភូមិ៥របស់ព្រះអរិយ ។ |
| | ១៣- អតប្បា | |
| | ១៤- សុទស្សា | |
| | ១៥- សុទស្សី | |
| | ១៦- អកនិដ្ឋា | |

| | | |
|---|---|---|
| អរូបភូមិមាន ៤ គឺ | ១- អាកាសានញ្ចាយតន | បញ្ចមជ្ឈានភូមិ ៤ ។ |
| | ២- វិញ្ញាណញ្ចាយតន | |
| | ៣- អាកិញ្ចញ្ញាយតន | |
| | ៤- នេវសញ្ញានាសញ្ញាយតន | |

រួមទាំងអស់៣១ភូមិឬ៣១ជាន់

បុគ្គលដែលអាស្រ័យនៅក្នុងភូមិទាំង៣១នោះមាន១២ចំពូក

www.budinst.gov.kh www.elibraryofcambodia.org

## បុគ្គលទាំង ១២ នោះចែកចេញជា ២ គឺៈ

១– បុថុជ្ជនបួនពួក ;

២– ព្រះអរិយៈប្រាំបីពួក ។

បុថុជ្ជន ៤ ពួកគឺ
- ១– ទុគ្គតិបុគ្គល ;
- ២– សុគតិបុគ្គល ;
- ៣– ទ្វិហេតុកបុគ្គល ;
- ៤– តិហេតុកបុគ្គល ។

ព្រះអរិយៈ ៨ ពួកគឺ
- ១– សោតាបត្តិមគ្គ ;
- ២– សកិទាគាមិមគ្គ ;
- ៣– អនាគាមិមគ្គ ;
- ៤– អរហត្តមគ្គ ;
- ៥– សោតាបត្តិផល ;
- ៦– សកិទាគាមិផល ;
- ៧– អនាគាមិផល ;
- ៨– អរហត្តផល ;

www.budinst.gov.kh www.elibraryofcambodia.org

## ភូមិប្រកបដោយបុគ្គល

១- ក្នុងចំនួនបុគ្គល ១២ ចំពូកដែលបានពោលរួចមកហើយ បុគ្គលដែលកើតក្នុងអបាយភូមិទាំង ៤ មានតែទុគ្គតិបុគ្គល ១ ពួក ។

## រួម ៤ ភូមិបានបុគ្គល ៤ ពួក

២- មនុស្សនឹងចាតុម្មហារាជិកា ទាំងពីរភូមិនោះបានដល់បុគ្គល ១១ ពួកគឺសុគតិបុគ្គល ១ ពួក ទ្វិហេតុកបុគ្គល ១ ពួក តិហេតុកបុគ្គល ១ ពួកព្រះអរិយបុគ្គលទាំង ៨ ពួក រួមជា ១១ ។

## រួម ២ ភូមិបានបុគ្គល ២២ ពួក

៣- តាំងពីតាវតឹសាដល់បរនិម្មិតវសវត្តី ទេវតា ៥ ភូមិនោះ បានដល់បុគ្គល ១០ ពួក គឺទ្វិហេតុកបុគ្គល ១ ពួក តិហេតុកបុគ្គល ១ ពួកព្រះអរិយបុគ្គល ៨ ពួក រួមជា ១០,

## រួម ៥ ភូមិបានបុគ្គល ៥០

៤- ក្នុងរូបព្រហ្ម ១០ ភូមិ គឺព្រហ្មបារិសជ្ជាដល់វេហប្ផលានោះបានដល់បុគ្គល ៩ ពួក គឺតិហេតុកបុគ្គល ១ ពួកនឹងព្រះអរិយបុគ្គល ៨ ពួក,

## រួម ១០ ភូមិបានបុគ្គល ៩០

៥- ក្នុងអសញ្ញីសត្តាភូមិនោះ កើតបានតែសុគតិបុគ្គលតែមួយពួកប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

៦- ក្នុងសុទ្ធាវាសទ៥ភូមិគឺ១-អវិហា, ២-អតប្បា, ៣-សុទស្សា, ៤-សុទស្សី,

៥- អកនិដ្ឋ នោះកើតបានតែបុគ្គល៣ពួកគឺ: ១-អនាគាមិផលបុគ្គល; ២- អរហត្តមគ្គបុគ្គល; ៣- អរហត្តផលបុគ្គល,

រួម៥ភូមិបានបុគ្គល១៥

៧- ក្នុងអរូបព្រហ្ម ៤ ភូមិនោះកើតបានតែបុគ្គល ៨ ពួក គឺតិហេតុកបុគ្គល ១ពួក, ព្រះអរិយ៧ពួក (វៀរសោតាបត្តិមគ្គបុគ្គល)

រួម ៤ ភូមិបានបុគ្គល៣២ ។

| | | |
|---|---|---|
| | ១- អបាយភូមិ៤ | មានបុគ្គល៤ |
| | ២- មនុស្ស, ចាតុម្មហារាជិកា | " ២២ |
| | ៣- ទេវតា៥ភូមិ | " ៥០ |
| រួមទាំងអស់ | ៤- រូបព្រហ្ម១០ភូមិ | " ៩០ |
| | ៥- អសញ្ញិសត្តា | " ១ |
| | ៦- សុទ្ធាវាស៥ភូមិ | " ១៥ |
| | ៧- អរូបព្រហ្ម៤ភូមិ | " ៣២ |

រួមជា២១៤បុគ្គល

www.budinst.gov.kh www.elibraryofcambodia.org

ប្រភេទចិត្តរបស់បុគ្គល ១១ ចំពូកក្នុងកាមភព ១១ ជាន់

១- ទុគ្គតិបុគ្គលកំណត់ចិត្ត ៣៧ គឺចិត្តជា
- អកុសលវិបាក៧
- កុសលវិបាក៨
- មហាកុសល៨
- អកុសល១២
- អហេតុកកិរិយា២វៀរហសិតុប្បាទ ;

២- សុគតិនិងទ្វិហេតុកបុគ្គលកំណត់ចិត្ត៤១គឺចិត្តជា
- កុសល-អកុសលវិបាក១៥
- មហាកុសល ៨
- អកុសល ១២
- មហាវិបាកវិប្បយុត្ត ៤
- អហេតុកកិរិយា២វៀរហសិ-តុប្បាទ ;

៣- តិហេតុកបុគ្គលកំណត់ចិត្ត៤៥ គឺចិត្តជា
- អសោភណ២៩វៀរហសិតុប្បាទ
- មហាកុសល ៨
- មហាវិបាក ៨

៤- សោតាបត្តិបុគ្គលនិងសកិទាគាមិបុគ្គលកំណត់ចិត្ត ៤១ គឺចិត្តជា
- មហាកុសល ៨
- មហាវិបាក ៨
- អកុសល៧វៀរទិដ្ឋិគត-សម្បយុត្ត៤និងវិចិកិច្ឆា
- សោតាបត្តិផល ១
- អហេតុក១៧វៀរហសិ-តុប្បាទ ;

www.budinst.gov.kh www.elibraryofcambodia.org

៥_ អនាគាមិបុគ្គលកំណត់ចិត្ត ៣៩ គឺចិត្តជា
- មហាកុសល ៨
- មហាវិបាក ៨
- ទិដ្ឋិគតវិប្បយុត្ត ៤
- ឧទ្ធច្ច ១
- អហេតុក ១៧ វៀរហសិតុប្បាទ
- អនាគាមិផល ១

៦_ ព្រះអរហន្តកំណត់ចិត្ត ៣៥ គឺចិត្តជា
- កាមវិបាក ២៣
- កាមកិរិយា ១១
- អរហត្តផល ១

ចប់ប្រភេទចិត្តរបស់កាមបុគ្គលតែប៉ុណ្ណោះ

# ប្រភេទចិត្តរបស់រូបបុគ្គល

បឋមជ្ឈានព្រហ្មទាំង ៣ កំណត់ចិត្ត ៣៩ គឺចិត្តជា
- អកុសល ១០ វៀរទោសមូល
- អហេតុក ១១ វៀរ (ឃាន ២ ជិវ្ហា ២ កាយ ២ ហសិតុប្បាទ ១)
- កុសលលោកិយ ១៧
- រូបបឋមជ្ឈានវិបាក ១ ;

ទុតិយជ្ឈានព្រហ្មទាំង ៣ កំណត់ចិត្ត ៤០ គឺចិត្តជា
- អសោភណ ២១ វៀរ (ទោសមូល ២ ឃាន ២ ជិវ្ហា ២ កាយ ២ ហសិតុប្បាទ ២)
- កុសលលោកិយ ១៧
- រូបទុតិយ នឹងតតិយវិបាកទាំង ២ ;

តតិយជ្ឈានព្រហ្មទាំង ៣ កំណត់ចិត្ត ៣៩ គឺចិត្តជា
- អសោភណ ២១ វៀរ (ទោសមូល ២ ឃាន ២ ជិវ្ហា ២ កាយ ២ ហសិតុប្បាទ ១)
- កុសលលោកិយ ១៧
- រូបចតុត្ថជ្ឈានវិបាក ១ ;

www.budinst.gov.kh www.elibraryofcambodia.org

ព្រហ្មនៅក្នុងវេហប្ផលាកំណត់ ចិត្ត ៣៩ គឺចិត្តជា
- អសោភណៈ ២១ វៀរ (ទោសមូល ២ ឃាន ២ ជិវ្ហា ២ កាយ ២ ហសិតុប្បាទ២)
- កុសលលោកិយ ១៧
- រូបបញ្ចមជ្ឈានវិបាក១

ចប់ព្រហ្មបុថុជ្ជន

សុទ្ធាវាស ៥ ភូមិព្រហ្មអនាគាមិ កំណត់ចិត្ត ៣៥ គឺចិត្តជា
- អកុសល ៥ វៀរ (ទិដ្ឋិគតសម្បយុត្ត៤ ទោសមូល២ វិចិកិច្ឆា ២ )
- កុសលលោកិយ១៧
- អហេតុក១១ វៀរ(ឃាន ២ ជិវ្ហា២កាយ ២ ហសិតុប្បាទ ១)
- រូបបញ្ចមជ្ឈានវិបាក១)
- អនាគាមិផល១ ;

សុទ្ធាវាស ៥ ភូមិព្រហ្មអរហន្ត កំណត់ចិត្ត ៣១ គឺចិត្តជា
- អហេតុក១២ វៀរឃាន ២ ជិវ្ហា ២កាយ២
- កិរិយាលោកិយ ១៧
- រូបបញ្ចមជ្ឈានវិបាក១
- អរហត្តផល១

ចប់ប្រភេទចិត្តរបស់រូបបុគ្គល

# ប្រភេទចិត្តរបស់អរូបបុគ្គល

ព្រហ្មអាកាសានញ្ចាយតន កំណត់ចិត្ត២៤គឺចិត្តជា
- អកុសល១០វៀរទោសមូល ២
- មនោទ្វារាវជ្ជន ១
- មហាកុសល ៨
- អរូបាវចរកុសល ៤
- អាកាសានញ្ចាយតនវិបាក១ ;

www.budinst.gov.kh www.elibraryofcambodia.org

ព្រហ្មវិញ្ញាណញ្ចាយតន កំណត់ចិត្ត២៣គឺចិត្តជា

- អកុសល១០វៀរទោសមូល២
- មនោទ្វារាវជ្ជន ១
- មហាកុសល ៨
- អរូបកុសល ៣ វៀរអាកាសានញ្ចាយតន
- វិញ្ញាណញ្ចាយតនវិបាក ១

ព្រហ្មអាកិញ្ចញ្ញាយតន កំណត់ចិត្ត ២២គឺចិត្តជា

- អកុសល ១០ វៀរទោសមូល២
- មនោទ្វារាវជ្ជន ១
- មហាកុសល ៨
- អរូបកុសល២វៀរអាកាសនឹងវិញ្ញាណ
- អាកិញ្ចញ្ញាយតនវិបាក ១

ព្រហ្មនេវសញ្ញានាសញ្ញាយតន កំណត់ចិត្ត ២១គឺចិត្តជា

- អកុសល១០វៀរទោសមូល២
- មនោទ្វារាវជ្ជន ១
- មហាកុសល ៨
- នេវសញ្ញានាសញ្ញាយតនកុសល ១
- វិបាក ១

ចប់ប្រភេទចិត្តរបស់អរូបបុគ្គលជាបុថុជ្ជន

## ប្រភេទចិត្តរបស់ព្រះអរិយបុគ្គល

ព្រហ្មសោតា ១ សកិទាគា១ អនាគា១ ព្រះអរិយ ៣ នេះ ដកទិដ្ឋិគតសម្បយុត្ត នឹងវិចិកិច្ឆាចេញ ហើយរួមសោតាបត្តិផល សកិទាគាមិផល អនាគាមិផលចូលជាមួយគ្នា កំណត់ចិត្តដូច្នេះគឺ ក្នុងអាកាសានញ្ចា កំណត់ចិត្ត២០ ក្នុងវិញ្ញាណញ្ចា កំណត់ចិត្ត១៩ ក្នុងអាកិញ្ចញ្ញា កំណត់ចិត្ត១៨ ក្នុងនេវសញ្ញានាសញ្ញា កំណត់ចិត្ត ១៧ ។

ចប់ប្រភេទចិត្តរបស់ព្រះអរិយៈ

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| ព្រហ្មជាព្រះអរហន្តក្នុងអាកាសានញ្ចាកំណត់ចិត្ត ១៥ គឺចិត្តជា | មនោទ្វារ | ១ |
| | មហាកិរិយា | ៨ |
| | អរូបាវចរកិរិយា | ៤ |
| | អាកាសានញ្ចាយតនវិបាក | ១ |
| | អរហត្តផល | ១; |

| | | |
|---|---|---|
| ព្រហ្មជាព្រះអរហន្តក្នុងវិញ្ញាណញ្ចាកំណត់ចិត្ត ១៤ គឺចិត្តជា | មនោទ្វារ | ១ |
| | មហាកិរិយា | ៨ |
| | អរូបាវចរកិរិយា ៣ វៀរអាកាស | |
| | អាកាសានញ្ចាយតនវិបា | ១ |
| | អរហត្តផល | ១ |

| | | |
|---|---|---|
| ព្រហ្មជាព្រះអរហន្តក្នុងអាកិញ្ចញ្ញាកំណត់ចិត្ត ១៣ គឺចិត្តជា | មនោទ្វារ | ១ |
| | មហាកិរិយា | ៨ |
| | អរូបាវចរកិរិយា ២ វៀរអាកាសនឹងវិញ្ញាណ | |
| | អាកិញ្ចញ្ញាយតនវិបាក | ១ |
| | អរហត្តផល | ១ |

| | | |
|---|---|---|
| ព្រហ្មជាព្រះអរហន្តក្នុងនេវសញ្ញានាសញ្ញាកំណត់ចិត្ត ១២ គឺចិត្តជា | មនោទ្វារ | ១ |
| | មហាកិរិយា | ៨ |
| | នេវសញ្ញានាសញ្ញាយតនកិរិយា | ១ |
| | នេវសញ្ញានាសញ្ញាយតនវិបាក | ១ |
| | អរហត្តផល | ១ |

ចប់ប្រភេទចិត្តរបស់ព្រះអរហន្តក្នុងអរូបភូមិ

## គាថាសង្គហ

អសីតិ វីថិចិត្តានិ កាមេ រូបេ យថារហំ

ចតុសដ្ឋី តថារូបេ ទ្វេ ចត្តាឡីស លព្ភរេ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងកាមភព ១១ ភូមិ ប្រភេទវិថីចិត្តរបស់បុគ្គល ១២ ចំពូក ពោលដោយសង្ខេប មានចំនួនចិត្ត ៨០, ក្នុងរូបព្រហ្ម ១៦ ភូមិ ប្រភេទវិថីចិត្តរបស់បុគ្គល ៩ ចំពូក មានចំនួនចិត្ត ៦៤, ក្នុងអរូបព្រហ្ម ៤ ភូមិ ប្រភេទវិថីចិត្តរបស់បុគ្គល ៨ ចំពូក មានចំនួនចិត្ត ៤១ ។

ចប់ប្រភេទចិត្តរបស់បុគ្គលក្នុងភូមិទាំង ៣១ ជាន់

ចប់ប្រភេទទី ២

## ប្រភេទទី៣ពោលអំពីរូប

ប្រភេទទី ៣ សំដែងអំពីរូបទាំងឡាយ ដែលជាធម្មជាតិប្រែប្រួលកើតឡើងហើយវិនាសទៅវិញជាធម្មតា មិនរើសថាល្អ ឬអាក្រក់បុណ្យឬបាបគឺជាអព្យាក្រិត រូបនោះកើតឡើងហើយ មិនបានតាំងនៅជាស្ថាពរ តាមសភាពដើមឡើយ រមែងប្រែប្រួលទៅដោយនិរោធប្បច្ច័យ នឹងជាលំនៅនៃជរាព្យាធិមរណៈប៉ុណ្ណោះឯង សមដូចពុទ្ធភាសិតសំដែងថា:

រូប្បតីតិ ខោ ភិក្ខវេ តស្មា រូបន្តិ វុច្ចតិ ម្នាលភិក្ខុទាំងឡាយ ធម្មជាតិណាដែលប្រែប្រួល ឬពុកផុយវិនាសទៅ (តថាគត) ហៅធម្មជាតិនោះថារូប ព្រោះហេតុតែប្រែប្រួល (មិនតាំងនៅតាមសភាពដើម) ។

www.budinst.gov.kh www.elibraryofcambodia.org

## សំដែងធម្មជាតិរូប ៥ ប្រការគឺ:

១- រូបសមុទ្ទេស សំដែងអំពីរូបដោយសង្ខេប ;

២- រូបវិភាគ សំដែងអំពីរូបដោយចំណែក ;

៣- រូបសមុដ្ឋាន សំដែងអំពីបច្ច័យឲ្យកើតរូប ;

៤- រូបកលាប សំដែងអំពីរូបដែលកើតព្រមគ្នាជាពួក ៗ ;

៥- រូបបវត្តិក្កម សំដែងអំពីរូបដែលកើតដោយលំដាប់ ។

## ១- រូបសមុទ្ទេស

### រូបមាន ២ យ៉ាងគឺ:-

១- មហាភូតរូប ៤, ២- ឧបាទាយរូប ២៤ ។

### មហាភូតរូប ៤ នោះគឺ:

១- បឋវី; ២- អាបោ; ៣- តេជោ; ៤- វាយោ ។

### ឧបាទាយរូប ២៤ នោះគឺ:

១- បសាទរូប ៥;

២- គោចររូប ៤;

៣- ភាវរូប ២;

៤- ហទយរូប ១;

៥- ជីវិតរូប ១;

៦- បរិច្ឆេទរូប ១;

៧- អាហាររូប ១;

៨- វិញ្ញត្តិរូប ២;

៩- វិការរូប ៣;

១០- លក្ខណរូប ៤ ។

www.budinst.gov.kh www.elibraryofcambodia.org

# អធិប្បាយមហាភូតរូប

មហាភូត បែកជាពីបទគឺ (មហា + ភូត) មហាប្រែថា "ធំ" ភូតប្រែថា "ប្រាកដ" មហាភូតរូបមាន ៤ គឺ:

១-បឋវី ដី សម្រាប់ទំនុកបំរុងប្រាសាទរូបមិនឲ្យវិនាសមិនឲ្យធ្លាក់ចុះ;

២-អាបោ ទឹក សម្រាប់ធ្វើមិនឲ្យខ្ទាត់ខ្ទាយ;

៣-តេជោ ភ្លើង សម្រាប់អប់កំដៅទុកមិនឲ្យហើមស្អុយរលួយ;

៤-វាយោ ខ្យល់ សម្រាប់បក់ត្រឡប់ទៅមក ។

## ឧបាទាយរូប ២៤ គឺ:

បសាទរូប ៥ គឺ
- ១- ចក្ខុបសាទ បសាទគឺភ្នែក;
- ២- សោតបសាទ " ត្រចៀក;
- ៣- ឃានបសាទ " ច្រមុះ;
- ៤- ជីវ្ហាបសាទ " អណ្ដាត
- ៥- កាយបសាទ " កាយ ។

គោចររូប ៤ គឺ
- ១- រូបៈ រូប;
- ២- សទ្ទៈ សំឡេង;
- ៣- គន្ធៈ ក្លិន;
- ៤- រសៈ រស ។

ភាវរូប ២ គឺ
- ១- ឥត្ថីភាវៈ ប្រកាសភេទស្ត្រីឲ្យប្រាកដ;
- ២- បុរិសភាវៈ ប្រកាសភេទប្រុសឲ្យប្រាកដ ។

www.budinst.gov.kh www.elibraryofcambodia.org

ហទយរូប១ គឺ រូបដែលជាទីអាស្រ័យរបស់ចិត្តគឺឈាមរក្សាបេះដូងដែលនៅក្នុងសាច់បេះដូង ។

ជីវិតរូប ១ គឺ: រូបដែលរក្សានូវកម្មជរូបនឹងអាហាររូបគឺកវឡិង្កាហារ ។

បរិច្ឆេទរូប១ គឺ រូបដែលជាចន្លោះក្នុងកាយ ។

អាហាររូប ១ គឺ រូបទាំងដែលកើតអំពីអាហារផ្សេង ៗ ។

វិញ្ញត្តិរូប២គឺ
- ១- កាយវិញ្ញត្តិរូប គឺរូបដែលជាបច្ច័យឲ្យសម្រេចឥរិយាបថ៤ដោយវាយោធាតុដែលកើតអំពីចិត្ត;
- ២- វចីវិញ្ញត្តិរូប គឺរូបដែលជាបច្ច័យឲ្យបឋវីធាតុដែលកើតអំពីចិត្តខ្ទប់រូបឲ្យពោលភាសាផ្សេង ៗ ។

វិការរូប៣គឺ
- ១- រូបស្ស លហុតា ភាពនៃរូបស្រាល;
- ២- រូបស្ស មុទុតា ភាពនៃរូបទន់;
- ៣- រូបស្ស កម្មញ្ញតា ភាពនៃរូបគួរដល់ការងារ ។

លក្ខណរូប៤គឺ
- ១- រូបស្ស ឧបចយោ ការសន្សំនូវរូបតាំងពីបឋមដំរាបដល់កើតចក្ខុទសកៈ;
- ២- រូបស្ស សន្តតិ រូបដែលកើតតពីរូបមុន;
- ៣- រូបស្ស ជរតា ការគ្រាំគ្រានៃរូបទាំងពីរខាងដើម;
- ៤- រូបស្ស អនិច្ចតា ភាពនៃរូបទាំង៣ខាងដើមមិនទៀង ។

## អធិប្បាយឧបាទាយរូប

ឧបាទាយរូប ៗ ដែលកើតឡើងដោយអាស្រ័យមហាភូតរូបទាំង ៤, ឧបាទាយរូបនេះ បើមិនមានមហាភូតរូបទេ ក៏មិនអាចកើតឡើងតែឯកឯងបានឡើយ, ព្រោះហេតុនោះ ឧបាទាយរូប សំដៅសេចក្ដីថា រូបដែលអាស្រ័យមហាភូតរូបទាំង ៤ ។

www.budinst.gov.kh www.elibraryofcambodia.org

## គាថាសង្គហ

ភូតប្បសាទវិសយា ភាវោ ហទយមិច្ចបិ
ជីវិតាហាររូបេហិ អដ្ឋារសវិធំ តថា
បរិច្ឆេទោ ច វិញ្ញត្តិ វិការោ លក្ខណន្តិ ច
អនិប្ផន្នា ទសា ចេតិ អដ្ឋវីសវិធម្ភវេ ។

ភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ ជា ១៨ ហៅថា និប្ផន្នរូប, នៅសល់រូប ១០ ទៀតគឺ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ ហៅថា អនិប្ផន្នរូប ; និប្ផន្នរូប ១៨ អនិប្ផន្នរូប ១០ រួមជា ២៨ ។

ចប់រូបសមុទ្ទេសន័យ

## រូបវិភាគន័យ

១- បសាទរូប ៥ ហៅថា អជ្ឈត្តិករូប នៅសល់រូប ២៣ ហៅថា ពាហិររូប ។

២- វត្ថុរូប ៦ គឺ {បសាទរូប ៥
ហទយរូប ១} នៅសល់រូប ២២ ហៅថា អវត្ថុរូប ។

៣ ទ្វាររូប ៧ គឺ {បសាទរូប ៥
វិញ្ញត្តិរូប ២} នៅសល់រូប ២១ ហៅថា អទ្វាររូប ។

៤- ឥន្ទ្រិយរូប ៨ គឺ {បសាទរូប ៥
ភាវរូប ២
ជីវិតរូប ១} នៅសល់រូប ២០ ហៅថា អនិន្ទ្រិយរូប ។

www.budinst.gov.kh www.elibraryofcambodia.org

៥ - នុទ្បារិករូប ១២ គឺ { បសាទរូប ៥ / វិសយរូប ៧ } នៅសល់រូប ១៦ ហៅថាសុខុមរូប ។

នុទ្បារិករូប ១២ នេះមានឈ្មោះពីរយ៉ាងទៀតគឺ សន្តិករូប ១ សប្បដិឃរូប ១; ឯសុខុមរូប ១៦ មានឈ្មោះពីរយ៉ាងទៀតគឺ ទូររូប ១ អប្បដិឃរូប ១ ។

៦- កម្មជរូបមាន ១៨ គឺ
- កលាបរូប ៨
- អាកាសរូប ១
- បសាទរូប ៥
- ហទយរូប ១
- ជីវិតរូប ១
- ភាវរូប ២

ហៅថាឧបាទិន្នករូបផង នៅសល់រូប ១០ ហៅថានេវិកម្មជរូបផង ហៅអនុបាទិន្នករូបផង ។

៧- រូបាយតនៈហៅថាសនិទស្សនរូប នៅសល់រូប ២៧ ហៅថាអនិទស្សនរូប ។

៨ - គោចរគ្គាហិករូប ៥
- អសម្បត្តគាហ
  - ១- ចក្ខុបសាទ
  - ២- សោតបសាទ
- សម្បត្តគាហ
  - ៣- ឃានបសាទ
  - ៤- ជីវ្ហាបសាទ
  - ៥- កាយបសាទ

នៅសល់រូប ២៣ ហៅថា អគោចរគ្គាហិករូប ។

៩ - អវិនិព្ភោគរូបមាន ៨ គឺ
- រូប ឬ វណ្ណ ១
- គន្ធ ១
- រស ១
- ឱជា ១
- មហាភូតរូប ៤

នៅសល់រូប ២០ ហៅថាវិនិព្ភោគរូប ។

www.budinst.gov.kh — www.elibraryofcambodia.org

រូបដែលបានពោលមកហើយនេះមិនទាន់អស់ទេ នៅសល់រូបទៀតជាច្រើនដូចអាហតុករូប សប្បច្ចយរូប សាសវរូប សង្ខតរូប លោកិយរូប កាមាវចររូប អនារម្មណរូប អប្បហាតព្វរូប ឈ្មោះដែលបានពោលមកប៉ុណ្ណេះជាដើមសុទ្ធតែជាឈ្មោះរបស់រូបទាំងអស់ ។

ចប់រូបវិភាគន័យ

## រូបសមុដ្ឋានន័យ

រូបសមុដ្ឋានមាន ៤ គឺ
- កម្ម ១
- ចិត្ត ១
- ឧតុ ១
- អាហារ ១

៤ យ៉ាងនេះឲ្យសម្រេចកើតបានជារូបផ្សេងៗ គឺកម្មជរូប ចិត្តជរូប ឧតុជរូប និងអាហារជរូប

កម្មដែលឲ្យកើតរូបគឺ
- ចិត្តជាអកុសល ១២
- ចិត្តជាកាមាវចរកុសល ៨
- ចិត្តជារូបាវចរកុសល ៥

ចិត្តទាំង ២៥ នេះជាហេតុឲ្យកើតរូប ១៨ គឺកម្មជរូប ១៨ ។

ចិត្តដែលឲ្យកើតរូបគឺ
- កាមាវចរចិត្ត ៥៤ ដកទ្វិបញ្ចវិញ្ញាណ ១០ ចេញ
- រូបាវចរចិត្ត ១៥
- អរូបាវចរកុសលនិងកិរិយា ៨
- លោកុត្តរ ៨

ចិត្តទាំង ៧៥ នេះជាហេតុឲ្យកើតចិត្តជរូប ១៥ ។

ឧតុដែលឲ្យកើតរូបគឺ
- សីតតេជោធាតុ
- ឧណ្ហតេជោធាតុ

ធាតុ ២ យ៉ាងនេះជាហេតុឲ្យកើតឧតុជរូប ១៣

www.budinst.gov.kh www.elibraryofcambodia.org

រូបដែលកើតមកពីអាហារគឺ ឱជានៃអាហារផ្សេង ៗ ដែលជាហេតុឲ្យកើតអាហារជរូប ១២ ។

រូបដែលកើតមកពីកម្មគឺ
- អវិនិព្ភោគរូប ៨
- ឥន្ទ្រិយរូប ៨
- ហទយរូប ១
- បរិច្ឆេទរូប ១

រូប ១៨ នេះសម្រេចមកពីកុសលាកុសល ។

រូបដែលកើតមកពីចិត្តគឺ
- វិការរូប ៣
- វិញ្ញត្តិរូប ២
- សទ្ទរូប ១
- អវិនិព្ភោគរូប៨
- បរិច្ឆេទរូប ១

រូប ១៥ នេះសម្រេចមកពីចិត្ត ។

រូបដែលកើតមកពីឧតុគឺ
- សទ្ទរូប ១
- អវិនិព្ភោគរូប៨
- វិការរូប ៣
- បរិច្ឆេទរូប ១

រូប ១៣ នេះកើតមកពីឧតុ ទាំង ២ គឺសីតនឹងឧណ្ហ ។

រូបដែលកើតមកពីអាហារគឺ
- វិការរូប ៣
- អវិនិព្ភោគរូប ៨
- បរិច្ឆេទរូប ១

រូប ១២ នេះកើតមកពីឱជានៃអាហារផ្សេង ៗ ។

រូបទាំង ២៨ នេះ, រូបខ្លះកើតឡើងដោយសមុដ្ឋានមួយ ហៅថាឯកសមុដ្ឋាន, រូបខ្លះកើតឡើងដោយសមុដ្ឋានពីរ ហៅថាទ្វិសមុដ្ឋាន, រូបខ្លះកើតឡើងដោយសមុដ្ឋានបី ហៅថាតិសមុដ្ឋាន, រូបខ្លះកើតឡើងដោយសមុដ្ឋានបួន ហៅថាចតុសមុដ្ឋាន ។

www.budinst.gov.kh www.elibraryofcambodia.org

## ឯកសមុដ្ឋានិករូប

ហទយរូប ១ ឥន្ទ្រិយរូប៨ រួមជា៩ រូបកើតមកតែពីកម្ម; វិញ្ញត្តិរូប២ កើតមកតែពីចិត្ត ។

## ទ្វិសមុដ្ឋានិករូប

សទ្ទរូប ១ កើតមកតែពីចិត្តនឹងឧតុ ។

## តិសមុដ្ឋានិករូប

វិការរូប ៣ កើតមកពីចិត្ត, ឧតុនឹង អាហារ ។

## ចតុសមុដ្ឋានិករូប

អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ រួមជា ៩ រូប កើតមកពីកម្ម, ចិត្ត, ឧតុ, នឹង អាហារ ។

លក្ខណរូប ៤ នោះមិនមានសមុដ្ឋានទេ ព្រោះគ្រាន់តែជាលក្ខណៈប្រាប់អាការ នៃផលភនឹងមរណៈប៉ុណ្ណោះ ។

ចប់រូបសមុដ្ឋាននន័យ

## រូបកលាបន័យ

| | | |
|---|---|---|
| រូបកលាបមាន ២១ គឺ | កម្មជកលាប ៩<br>ចិត្តជកលាប ៦<br>ឧតុជកលាប ៤<br>អាហារជកលាប ២ | រួមជា ២១ រូប ។ |

www.budinst.gov.kh www.elibraryofcambodia.org

| | | | | |
|---|---|---|---|---|
| ១- អវិនិព្ភោគរូប ៨ នឹង ជីវិតរូប ១ រួមជា ៩ ហៅថាជីវិតនវកៈកលាប ដ៏ដ | ២ ចក្ខុបសាទ | ១ | ចក្ខុទសកៈ | ១០ |
| | ៣ សោតបសាទ | ១ | សោតទសក | ១០ |
| | ៤ ឃានបសាទ | ១ | ឃានទសក | ១០ |
| | ៥ ជិវ្ហាបសាទ | ១ | ជិវ្ហាទសក | ១០ |
| | ៦ កាយបសាទ | ១ | កាយទសក | ១០ |
| | ៧ ឥត្ថីភាវ | ១ | ឥត្ថីភាវទសក | ១០ |
| | ៨ បុរិសភាវ | ១ | បុរិសភាវទសក | ១០ |
| | ៩ វត្ថុរូប | ១ | វត្ថុទសក | ១០ |

## ចិត្តជកលាបមាន ៦ នោះគឺ:

| | | |
|---|---|---|
| ១- អវិនិព្ភោគរូប ៨ ដ៏ដ | ២- កាយវិញ្ញត្តិរូប ១ | =៩ |
| | ៣- វចីវិញ្ញត្តិរូបនឹងសទ្ទរូប ១ | =១០ |
| | ៤- វិការរូប ៣ | =១១ |
| | ៥- កាយវិញ្ញត្តិ ១ នឹងវិការរូប ៣ | =១២ |
| | ៦- វចីវិញ្ញត្តិ ១ នឹងសទ្ទរូប ១ នឹងវិការរូប ៣ | =១៣ |

www.budinst.gov.kh www.elibraryofcambodia.org

## ឧតុជ្ជកលាបមាន៤នោះគឺ

១- អវិនិព្ភោគរូប៨ ជី ផ
- ២– សទ្ទរូប ១ សទ្ទនវក ៩
- ៣– វិការរូប៣ លហុតាទិឯកាទសក ១១
- ៤– សទ្ទរូប ១ នឹងវិការរូប៣ សទ្ទលហុតាទិទ្វាទសក ១២

## អាហារជ្ជកលាបនោះមាន ២ គឺ

១- អវិនិព្ភោគរូប ៨ សុទ្ធកលាប ៨ ;

២- អវិនិព្ភោគរូប ៨ នឹងវិការរូប ៣ លហុតាទិឯកាទសក ១១ ។

## គាថាសង្គហា

កម្មចិត្តោតុកាហារ សមុដ្ឋានា យថាក្កមំ
នវ ច ចតុរោ ទ្វេតិ កលាបា ឯកវីសតិ

រូប ២៨ បើរាប់ដោយសមុដ្ឋានមាន ៤ គឺ កម្ម ចិត្ត ឧតុនឹងអាហារ បើរាប់ដោយកលាបវិញជាកម្មជកលាបមាន ៩ ចិត្តជកលាបមាន ៦ ឧតុជកលាបមាន ៤ នឹងអាហារជកលាបមាន ២ រួមជា ២១ កលាប ។

**ចប់រូបកលាបន័យ**

www.budinst.gov.kh www.elibraryofcambodia.org

# រូបបវត្តិក្កមន័យ

បដិសន្ធិមាន៤ នោះគឺ
- ១- អណ្ឌជ កើតអំពីស៊ុត
- ២- សំសេទជ កើតអំពីញើសក្អែល
- ៣- គព្ភសេយ្យក កើតអំពីមាតាបិតាឬកំណើតដេកក្នុងគភ៌
- ៤- ឧបបាតិក កើតពីកម្មផុតអំពីកំណើតទាំង៣ ខាងដើម ។

ពួកសត្វក្នុងកាមភពដែលមានឥន្ទ្រិយបរិបូណ៌ តែងបានរូប ២៨ គ្រប់គ្រាន់ក្នុងបវត្តិកាលខាងមុខអំពីបដិសន្ធិកាល, សំសេទជសត្វនិងឧបបាតិកសត្វ២ ពួកនេះតែងបានរូបបលាបគ្រប់ក្នុងវេលាបដិសន្ធិកាល ។ បុគ្គលដែលចុតិមកអំពីភពមុនហើយ បានទទួលបដិសន្ធិក្នុងភពនេះ ព្រមដោយបដិសន្ធិចិត្តនោះ កម្មជរូប ក៏រមែងបង្កើតព្រមគ្នា ដោយអាស្រ័យឧប្បាទខណៈរបស់បដិសន្ធិចិត្តដែលកើតឡើង ។

ក្នុងទីនេះពេលគព្ភសេយ្យកសត្វ និងអណ្ឌជសត្វ រូបដែលកើតជាមួយនឹងបដិសន្ធិចិត្តនោះមាន ៣០ ។

| | | |
|---|---|---|
| គព្ភសេយ្យកសត្វនិង អណ្ឌជសត្វ | កាយទសក = ១០ | |
| | ភាវទសក = ១០ | រួមជា ៣០ រូប |
| | វត្ថុទសក = ១០ | |

ចំណែកសំសេទជសត្វ និងឧបបាតិកសត្វនោះ មានរូបដែលកើតឡើងជាមួយនឹងបដិសន្ធិចិត្តនោះមាន ៧០ ។

www.budinst.gov.kh www.elibraryofcambodia.org

| | | | |
|---|---|---|---|
| សំសេទជសត្វ នឹង ឧបបាតិកសត្វ | ចក្ខុទសក | = ១០ រូប | |
| | សោតទសក | = ១០ រូប | |
| | ឃានទសក | = ១០ រូប | |
| | ជីវ្ហាទសក | = ១០ រូប | រូបជា ៧០ រូប |
| | កាយទសក | = ១០ រូប | |
| | ភាវទសក | = ១០ រូប | |
| | វត្ថុទសក | = ១០ រូប | |

រូបប៉ុណ្ណោះជាកម្មជរូប តែងកើតមកអំពីឧប្បាទខណៈ ឋិតិខណៈ និងភង្គខណៈ កើតឡើងបានទាំង ៣ ខណៈ, ចិត្តជរូបកើតអំពីឧប្បាទខណៈរបស់ភវង្គ ចំណែកឧតុជរូបនោះ ក៏កើតអំពីឋិតិខណៈរបស់បដិសន្ធិតទៅគ្រប់ ៗ ឋិតិខណៈរហូតទៅដល់ចុតិចិត្ត, ចំណែកអាហារជរូបនោះ បើមាតាទទួលទានអាហារចូលទៅ ក៏កើតអាហារជរូបឡើង ឯទារកចំរើនវ័យតមកជាលំដាប់ ។

តាំងតែពីពេលនោះមក រូបសមុដ្ឋានទាំង ៤ ក៏ចំរើនជាប់គ្នាមកមិនដាច់ ដូចជាអណ្តាតប្រទីប ឬដូចខ្សែទឹកដែលហូរ កើតឡើងគ្រប់ខណៈដរាបដល់ចុតិកាល, កាលបើសត្វចុតិហើយ ចាប់តាំងអំពីចិត្តចុតិថយចុះមកដល់ ១៧ វិថីចិត្ត តអំពីចិត្តនោះមក កម្មជរូបក៏ឈប់មិនបង្កើតទៅទៀត ។

កម្មជរូបដែលមានមកពីមុនក៏រលត់ទៅព្រមជាមួយនឹងចុតិចិត្ត តពីនោះមក ចិត្តជរូបនឹងអាហារជរូបក៏រលត់ទៅដែរ នៅសល់តែឧតុជរូប

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះ ដែលកើតតៗ មក ដរាបដល់អស់ភស្ម័យហើយបានឡើងជា

ឧទ្ធុមាតកៈទើបរលត់ ។

## មើលភាពវិថីចុតិនឹងបដិសន្ធិ

ឧប្បាទ ..... ០

បដិសន្ធិ ឋិតិ ..... ០ ចិត្តជាបដិសន្ធិ

ភង្គ ..... ០

\+

ភាពចុតិនឹងបដិសន្ធិ ខណៈរបស់ចិត្ត១៧មុនចុតិ

| | | |
|---|---|---|
| ០០០ | ភវង្គ | ១ |
| ០០០ | ភវង្គ | ១ |
| ០០០ | ភវង្គ | ១ |
| ០០០ | ភវង្គ | ១ |
| ០០០ | ភវង្គ | ១ |
| ០០០ | ភវង្គ | ១ |
| ០០០ | ភវង្គចលនៈ | ១ |
| ០០០ | ភវង្គុបច្ឆេទៈ | ១ |
| ០០០ | មនោទ្វារាវជ្ជនៈ | ១ |
| ០០០ | ជវនៈ | ១ |
| ០០០ | ជវនៈ | ១ |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ជវនៈ | ១ |
| ជវនៈ | ១ |
| ជវនៈ | ១ |
| តទាលម្ពណៈ | ១ |
| តទាលម្ពណៈ | ១ |
| ចុតិចិត្ត | ១ |

## គាថាសង្គហ

ឥចេវំ មតសត្តានំ　　បុនទេវ ភវន្តរេ
បដិសន្ធិមុបាទាយ　　តថារូបំ បវត្តតិ ។

សត្វដែលបានចុតិចុះចាកភពនេះហើយ លុះបានទៅបដិសន្ធិក្នុងភពដទៃទៀត កម្មជរូប ចិត្តជរូប ឧតុជរូប និងអាហារជរូប ទាំង៤ នេះក៏កើតមានតទៅទៀត ដូចបានពោលមកហើយ ។

ចប់កាមបុគ្គល

## រូបព្រហ្ម

ឧបបាតិកបដិសន្ធិក្នុងរូបព្រហ្ម ១៥ ភពនោះមានរូប ៣៩ គឺ

| | | |
|---|---|---|
| ចក្ខុទសក | ១០ | រួមជា ៣៩ រូប |
| សោតទសក | ១០ | |
| វត្ថុទសក | ១០ | |
| ជីវិតនវក | ៩ | |

www.budinst.gov.kh　　www.elibraryofcambodia.org

កាលរូបព្រហ្មបដិសន្ធិនោះ កម្មជរូប ៣៩ នេះក៏កើតឡើងព្រមដោយឧប្បាទខណៈរបស់បដិសន្ធិចិត្ត លុះដល់បវត្តិកាលនោះ ចិត្តជរូបនឹងឧតុជរូបក៏កើតឡើងតទៅ តែអាហារជរូបមិនមានឡើយ ព្រោះព្រហ្មមិនទទួលទានអាហារ ព្រោះហេតុដូច្នោះ ក្នុងរូបព្រហ្ម ១៥ ភពនោះ មានរូបដែលកើតឡើងបានតែត្រឹម ២៣ ប៉ុណ្ណោះ, ចំណែកឧបបាតិកបដិសន្ធិក្នុងព្រហ្មអសញ្ញិសត្តានោះមានតែជីវិតនវក ៩ រូបប៉ុណ្ណោះ ដែលកើតជាមួយនឹងបដិសន្ធិ រូបក្រៅអំពីនោះកើតក្នុងបវត្តិកាល ។

រូបដែលកើតក្នុងអសញ្ញិសត្តាព្រហ្មមានតែត្រឹម ១៧រូប ។

| | | |
|---|---|---|
| រូប ១៧ ដែលអសញ្ញិសត្តាបាននោះគឺ | ជីវិតនវក ៩<br>វិការរូប ៣<br>លក្ខណរូប ៤<br>អាកាសរូប ១ | រួមជា១៧ |

ចំណែកអរូបព្រហ្មមិនមានរូបដូចពោលមកហើយនោះទេ ព្រោះអរូបព្រហ្មកើតដោយនាមបដិសន្ធិ ។

## គាថាសង្គហ

អដ្ឋវីសតិ កាមេសុ ហោន្តិ តេវីស រូបីសុ
សត្តរសេវសញ្ញីនំ អរូបេ នត្ថិ កិញ្ចិបិ ។

ក្នុងកាមភព ១៩ សត្វដែលកើតឡើងដោយបដិសន្ធិទាំង ៤ មានរូបដែលកើតឡើង ២៨, រូបព្រហ្ម ១៥ ភព កើតឡើងដោយឧបបាតិកបដិ

www.budinst.gov.kh www.elibraryofcambodia.org

សន្ធិមានរូប ២៣ ក្នុងអសញ្ញិសត្តាព្រហ្ម១ភព មានរូបតែ ១៧ ប៉ុណ្ណោះ, ក្នុងអរូបព្រហ្ម ៤ ភពនោះ មិនមានរូបកើតឡើងទេ ។

ចប់រូបបវត្តិកមន័យ

ចប់ប្រភេទទី ៣

# ប្រភេទទី ៤ ពោលពីព្រះនិព្វាន

## និព្វាន

ពាក្យថានិព្វាន ជាឈ្មោះនៃធម្មជាតិរលត់ភ្លើងទុក្ខភ្លើងកិលេស, ជាធម្មជាតិចេញផុតពីព្រៃស្នាប់គឺតណ្ហាទាំង ១០៨, ជាស្ថានសន្តិសុខគឺសុខស្ងប់ផុតអំពីតណ្ហា ដែលជាហេតុនាំឲ្យកើតទុក្ខទាំងពួង ជាឯកន្តបរមសុខ សុខឯកក្រៃលែង មិនលាយទៅដោយទុក្ខ ជាលោកុត្តរធម៌ខ្ពស់បំផុតជាងធម៌ទាំងពួងក្នុងលោក ។

ន័យមួយទៀតព្រះនិព្វាននេះ មានការរម្ងាប់បង់នូវកិលេសទាំងឡាយមានលោភ ទោស មោហ អវិជ្ជា តណ្ហាជាដើម ជាលក្ខណៈ, មានមិនច្យុតិមិនលុះក្នុងអំណាចនៃសង្ខតធម៌ជាកិច្ច, មានការប្រាសចាកសង្ខតនិមិត្ត ឬរម្ងាប់នូវបបញ្ចធម៌ជាផល, និព្វានមានតែមួយមិនមានពីរទេ តែបើពោលដោយបរិយាយ មានពីរក៏មាន មាន៣ក៏មាន ។

www.budinst.gov.kh www.elibraryofcambodia.org

## និព្វានមាន ២ គោះគឺ:

១- សឧបាទិសេសនិព្វាន រលត់តែកិលេសឯបញ្ចក្ខន្ធនៅមិនទាន់រលត់ ។

២- អនុបាទិសេសនិព្វាន រលត់កិលេសផង រលត់បញ្ចក្ខន្ធផង ។

## និព្វានមាន៣គោះគឺ :

១- សុញ្ញតនិព្វាន សូន្យអកុសល បុជាអារម្មណ៍នៃអរិយមគ្គដែលកើតក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនាមានអនត្តាជាអារម្មណ៍ ;

២- អនិមិត្តនិព្វាន មិនមានអកុសលកើតឡើងបាន រជាអារម្មណ៍នៃអរិយមគ្គដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិនីវិបស្សនាមានអនិច្ចលក្ខណជាអារម្មណ៍ ;

៣- អប្បណិហិតនិព្វាន មិនមានសេចក្តីអាល័យគឺតណ្ហាទាំងពួងបុជាអារម្មណ៍នៃអរិយមគ្គដែលកើតឡើងក្នុងលំដាប់នៃវុដ្ឋានគាមិ-នីវិបស្សនាមានទុក្ខលក្ខណៈជាអារម្មណ៍ ។

## កិត្តិគុណរបស់និព្វានមាន៨យ៉ាងគឺ

១- មទនិម្មទនោ និព្វានធម៌តែងញុំាញីនូវសេចក្តីស្រវឹងទាំងពួង មានស្រវឹងក្នុងវ័យជាដើម ;

www.budinst.gov.kh www.elibraryofcambodia.org

២- បិចាសវិនយោ និព្វានធម៌តែងបន្សាបន្ទូវសេចក្តីស្រេក
ឃ្លានក្នុងបញ្ចវិធកាមគុណ ;

៣- អាលយសមុគ្ឃាតោ និព្វានធម៌តែងគាស់រំលើងចោល
នូវសេចក្តីអាល័យក្នុងបញ្ចវិធកាមគុណ ;

៤- វដ្ដុបច្ឆេទោ និព្វានធម៌តែងកាត់ចោលនូវដំណើរវិលវល់
ត្រឡប់ទៅកាន់ភពទាំង ៣ ;

៥- តណ្ហាក្ខយោ និព្វានធម៌តែងដល់នូវកិរិយាអស់ទៅនៃតណ្ហា ;

៦- វិរាគោ និព្វានធម៌តែងដល់នូវកិរិយាប្រាសចាកភាគទិក្កិលេស ;

៧- និរោធោ និព្វានធម៌តែងដល់នូវសេចក្តីរលត់ចាកតណ្ហា ទាំងពួង ;

៨- និព្វានំ និព្វានតែងចេញចាកកំនប្រទេស (ទីញាតស្បាត) គឺ
តណ្ហា ។

## គុណរបស់និព្វានមាន ៣ ២យ៉ាងទៀតគឺ

១- អជាតិ- និព្វានមិនមានកំណើត ;

២- អជរំ និព្វានមិនមានគ្រាំគ្រា ;

៣- អព្យាធិ និព្វានមិនមានព្យាធិ ;

៤- និព្ភយំ និព្វានមិនមានភ័យ ;

៥- អសង្ខតំ និព្វានមិនមានបច្ច័យប្រជុំតាក់តែង ;

www.budinst.gov.kh www.elibraryofcambodia.org

៦- ភវភង្គំ  និព្វានទំលាយនូវត្រ័យលោក;

៧- សុខំ  និព្វានជាបរមសុខ;

៨- សីតំ  និព្វានដ៏ត្រជាក់;

៩- ខេមំ  និព្វានដ៏ក្សេម;

១០- តាណំ  និព្វានជាទីពឹងដល់ព្រះអរិយ;

១១- លេណំ  និព្វានជាទីពួនអំពីមច្ចុ;

១២- និច្ចំ  និព្វានទៀងមិនបានប្រែប្រួល;

១៣- អចលំ  និព្វានមិនកំរើក;

១៤- ធុវស្សសំ  និព្វានទៀងប្រាកដ;

១៥- អវដ្តសារំ  និព្វានមានខ្លឹមសារមិនមានវិលត្រឡប់;

១៦- សុខមគ្គនំ  និព្វានញុំាំញុីនូវសុខក្នុងមនុស្ស និងសុខក្នុងឋានសួគ៌;

១៧- ទុក្ខមគ្គនំ  និព្វានញុំាំញីនូវសេចក្តីឃ្លានបាយ;

១៨- បិបាសញ្ញនយំ  និព្វានបន្ទោបង់នូវសេចក្តីស្រេកទឹក;

១៩- អនាលយំ  និព្វានមិនមានអាល័យ;

២០- សមុគ្ឃាដវដ្តំ ធរជ្ជសំ និព្វានដកនូវទោសដែលដោតនៅក្នុងចិត្តដូចពិសពស់;

www.budinst.gov.kh www.elibraryofcambodia.org

២១- វិសង្ខារំ និព្វានប្រាសចាកសង្ខារគឺនាមនិងរូប;

២២- វិវដ្ដំ និព្វានប្រាសចាកទោសទាំងឡាយ;

២៣- តណ្ហាក្ខយំ និព្វានជាទីក្ស័យនៃតណ្ហា;

២៤- វិភវំ និព្វានប្រាសចាកត្រ័យភព;

២៥- វិរាគំ និព្វានប្រាសចាករាគៈ ;

២៦- វីតមោហំ និព្វានប្រាសចាកមោហៈ ;

២៧- និរោធំ និព្វានរលត់ទុក្ខទាំងពួង;

២៨- អនិមិត្តំ និព្វានមិនមាននិមិត្ត ;

២៩- សន្តភាវំ និព្វានជាសភាវៈរម្ងាប់កិលេស;

០- អរសារកំ និព្វានមិនមានរសគឺតណ្ហា;

៣១- អប្យសាសញ្ញំ និព្វានលះចេញនូវសេចក្ដីរីករាយនៃចិត្ត;

៣២- អមតំ និព្វានមិនចេះស្លាប់ ។

## កិត្តិនាមរបស់និព្វានមាន ៤៦ យ៉ាងគឺ

១- មោក្ខោ សភាវៈរួចផុតស្រឡះចាករាគាទិកិលេស;

២- និរោធោ សភាវៈរលត់នៃរាគាទិកិលេស ឬជាធម៌ជាទីរលត់នៃសញ្ញានិងវេទនា ជាធម៌ដែលផុតអំណាច ;

៣- និព្វានំ ធម្មជាតិចេញចាកតណ្ហា ឬជាធម្មជាតិចេញផុតចាកតណ្ហាគឺធម្មជាតិរលត់នៃតណ្ហា;

www.budinst.gov.kh www.elibraryofcambodia.org

៤- ធីរោ សភាវៈជាគោរះប្ដុជាប្រទីបជាទីពឹង ;

៥- តណ្ហាក្ខយោ និព្វានជាសភាវៈញាំងតណ្ហាឲ្យអស់ទៅ ឬថាសភាវៈគសរម្រន់នូវតណ្ហា ;

៦- បរំ និព្វានជាធម្មជាតិដ៏ឧត្តម ព្រោះជាសត្រូវដល់រាគាទិកិលេស ;

៧- តាណំ និព្វានជាធម្មជាតិរក្សាសត្វឲ្យផុតចាកអបាយ ;

៨- លេណំ និព្វានជាទីជ្រកកោន ឬថាជាទីពឹងពួន ;

៩- អរូបំ និព្វានមិនមានរូបកាយ ;

១០- សន្តំ និព្វានជាទីរម្ងាប់នូវកិលេស ;

១១- សច្ចំ និព្វានជាធម្មជាតិទៀងពិត ;

១២- អនាលយំ និព្វានមិនមានកន្លង់មិនមានអាល័យ ;

១៣- អសង្ខតំ និព្វានមិនមានបច្ច័យ គឺកុសលាកុសលកម្មប្រជុំតាក់តែងទៀត ;

១៤- សិវំ និព្វានជាធម្មជាតិធ្វើនូវសេចក្ដីក្សេមក្សាន្ត ;

១៥- អមតំ និព្វានជាធម្មជាតិមិនស្លាប់ ;

១៦- សុទុទ្ទសំ និព្វានគឺបុគ្គលឃើញបានដោយកម្រក្រពេក ;

១៧- បរាយនំ និព្វានជាធម្មជាតិគឺព្រះអរិយបុគ្គលគប្បីដល់ ;

១៨- សរណំ និព្វានជាទីរលឹក ;

www.budinst.gov.kh www.elibraryofcambodia.org

១៩- អនីតិកំ និព្វានជាធម្មជាតិមិនមានអន្តរាយ ;

២០- អនាសវំ និព្វានមិនមានអាសវៈ ;

២១- ធុវំ និព្វានជាធម្មជាតទៀងទាត់ ;

២២- អនិទស្សនំ និព្វានជាធម្មជាតមើលមិនឃើញដោយភ្នែក ;

២៣- អកតំ និព្វានជាធម្មជាតគឺបុគ្គលមិនអាចនឹងធ្វើបាន ;

២៤- អបលោកិតំ និព្វានជាធម្មជាតិគឺបុគ្គលមិនអាចប្រាប់បាន ;

២៥- និបុណំ និព្វានជាធម្មជាតិជម្រះនូវកិលេស ឬថាធម្មជាតិដ៏ល្អិត ;

២៦- អនន្តំ និព្វានជាធម្មជាតិរកទីបំផុតគ្មាន ;

២៧- អក្ខរំ និព្វានជាសត្រូវដល់សង្សារ ;

២៨- ទុក្ខក្ខយោ សភាវៈវិនាសញ៉ាំងសេចក្តីទុក្ខឲ្យអស់ទៅ ;

២៩- អព្យាបជ្ឈំ និព្វានជាធម្មជាតិឥតមានព្យាបាទ ;

៣០- វិវដ្តំ និព្វានជាធម្មជាតិមានវដ្តៈទៅប្រាសហើយ ;

៣១- ខេមំ និព្វានជាធម្មជាតិក្សេមចាកភ័យឬថាជាទីអស់ទៅនៃភ្លើងគឺភគៈជាដើម ;

៣២- កេវលំ និព្វានជាធម្មជាតិមិនច្របូកច្របល់ដោយសង្ខារ ;

៣៣- អបវគ្គោ សភាវៈឥតបក្សពួកឬប្រាសចាកសង្ខារ ;

៣៤- វិភគោ សភាវៈប្រាសចាកភគៈ ;

www.budinst.gov.kh www.elibraryofcambodia.org

៣៥- បណីតំ និព្វានជាវត្ថុដ៏ប្រសើរលើសវត្ថុក្នុងលោក;

៣៦- អច្ចុតំ និព្វានជាធម្មជាតិនៅ មិនឃ្លៀងឃ្លាត;

៣៧- បទំ និព្វានជាផ្លូវដែលព្រះអរិយបុគ្គលគប្បីដល់;

៣៨- យោគក្ខេមំ និព្វានជាធម្មជាតិអស់ទៅនៃយោគទាំង ៤;

៣៩- តាណំ និព្វានជាត្រើយនៃសង្សារឬថាអាចរម្ងាប់នូវកំដៅនៃសង្សារទុក្ខ;

៤០- មុត្តិ ជាធម្មជាតិផុតចាកកិលេស;

៤១- សន្តិ ជាធម្មជាតិសម្រាប់រម្ងាប់ទុក្ខឬថាជាគុណជាតិ

៤២- វិសុទ្ធិ ជាធម្មជាតិដ៏ស្អាតដោយវិសេសឬថាបរិសុទ្ធចាករាគាទិកិលេស;

៤៣- វិមុត្តិ ជាធម្មជាតិរួចចាកសង្ខារធម៌ ឬថាជាធម្មជាតិផុតស្រឡះចាកធម៌ជាគ្រឿងសៅហ្មងទាំងពួង;

៤៤- អសង្ខតធាតុ ជាធាតុដែលសង្ខារធម៌ទាំងពួងធ្វើមិនបាន;

៤៥- សុទ្ធិ ជាធម្មជាតិផូរផង់ឬថាជាធម្មជាតិដ៏ថ្លាស្អាត;

៤៦- និព្វុតិ ជាធម្មជាតិដែលរលត់នូវសេចក្តីក្រវល់ក្រវាយ

ចប់ប្រភេទទី ៤

ចប់អភិធម្ម ៧ គម្ពីរសង្ខេប

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# របៀបរៀនអភិធម្ម

របៀបរៀនអភិធម្មនេះ សូមចាត់ទុកជាមាតិកាដូចមានតទៅនេះ,

១- ត្រូវឧស្សាហ៍ទន្ទេញពួកធម៌មួយក្រុមៗ ដរាបដល់ចាំស្ទាត់ឥតមានភាន់ច្រឡំ ។

២- ត្រូវចេះរិប្រែសព្ទមួយៗ ឲ្យប្រាកដ ។

៣- ត្រូវពិចារណាសេចក្ដីក្នុងមាតិកាធម៌មួយ ៗ ឲ្យយល់ចូលចិត្តច្បាស់លាស់ សឹមទន្ទេញនឹងពិចារណា មាតិកាធម៌តទៅទៀត ។

៤- បើមានសេចក្ដីសង្ស័យមិនច្បាស់លាស់ត្រង់បទណា ត្រូវពិចារណានឹងសាកសួរអ្នកចេះដឹងត្រង់បទនោះ ឲ្យយល់ចូលចិត្តប្រាកដ កុំរំលងសេចក្ដីសង្ស័យចោលហើយរៀនទៅមុខទៀត ។

៥- ត្រូវឧស្សាហ៍សូត្រនឹងសាកប្លាឲ្យញឹកញាប់ ដើម្បីកុំឲ្យភ្លាំងភ្លេចទៅវិញ ។

បើសិក្ខាកាមជនបានយកចិត្តទុកដាក់ប្រព្រឹត្តតាមរបៀបដែលបានចាត់ទុកជាមាតិកាដូចខាងលើនេះហើយ មុខជាលោកអ្នកនឹងបានសម្រេចផលល្អនឹងដល់ទីគាប់ចិត្តតាមសេចក្ដីប្រាថ្នាពុំខាន ។

ធ.វិ.



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org